ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស
(គ.ជ.ប.ជ)

# អបអរសាទរ

## ពិធីប្រកាសជាផ្លូវការ

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
## រចនាសម្ព័ន្ធថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ
## និងផែនការសកម្មភាពជាតិ ជំហានទី២ (២០១៤-២០១៨)

ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥

នៅសាលប្រជុំក្រសួងមហាផ្ទៃ

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

វ៉ន_សិរីលក្ខិណា

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ពិធី

## ប្រកាសជាផ្លូវការណ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
## រចនាសម្ព័ន្ធថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងផែនការសកម្មភាពជាតិ
## ជំហានទី២(២០១៤-២០១៨)

ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥ (ពេលរសៀល) នៅសាលប្រជុំក្រសួងមហាផ្ទៃអគារ S

**របៀបវារៈ**

| ម៉ោង | ការពិពណ៌នា |
|---|---|
| ១៣.០០-១៣.៤០ | ជួបជុំសមាជិក និងចុះឈ្មោះ (អាហារសំរ៉ន់) |
| ១៣.៤០-១៣.៥០ | ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និងអង្គទូតអញ្ជើញមកដល់ |
| ១៣.៥០-១៤.០០ | ឯកឧត្តមប្រធានគណៈអធិបតីអញ្ជើញមកដល់ |
| ១៤.០០-១៤.១០ | ប្រកាសហេតុ និងគោរពភ្លេងជាតិ |
| *កម្មវិធីទី១: ប្រកាសគណៈកម្មាធិការជាតិ នឹងរចនាសម្ព័ន្ធ* | |
| ១៤:១០-១៤:២៥ | ធ្វើរបាយការសង្ខេបស្តីពីដំណើរការនៃការរៀបចំរចនាសម្ព័ន្ធ យន្តការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធាន អចិន្ត្រៃយ៍ គ.ជ.ប.ជ |
| ១៤:២៥-១៥:០០ | ប្រកាសព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្តីសម្រេចពាក់ព័ន្ធនានា:<br>- ព្រះរាជក្រឹត្យស្តីពីការបង្កើត គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)<br>- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ស្តីពីការតែងតាំងសមាសភាព គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ<br>- អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការ ដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>- សេចក្តីសម្រេចរបស់គណៈកម្មាធិកាជាតិស្តីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស<br>- សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ |

រ៉ែន_សិរីលក្ខិណា

| | |
|---|---|
| ***កម្មវិធីទី២ : ប្រកាសមន្ត្រីដឹកនាំអគ្គលេខាធិការដ្ឋាន*** | |
| ១៥:០០-១៥:២៥ | -ព្រះរាជក្រឹត្យស្តីពីការតែងតាំងអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>-អនុក្រឹត្យស្តីពីការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិ និង មន្ត្រីរាជការ<br>- អនុក្រឹត្យស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ |
| ***កម្មវិធីទី៣ : ពិធីប្រគល់ត្រា*** | |
| ១៥:២៥-១៥:៥០ | ពិធីប្រគល់ត្រា និងសេចក្តីសម្រេចៈ<br>**ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី ប្រធាន គ.ជ.ប.ជ** ប្រគល់<br>-ត្រាគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជូន លោកជំទាវ ជូ ប៊ុនអេង ជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ<br>-ត្រាអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជូន ឯកឧត្តម ឧត្តមសេនីយ៍ឯក ថោង សំអាត អគ្គលេខាធិការ<br>-ត្រារាជធានី ខេត្តទាំង២៥ សេចក្តីសម្រេចសមាសភាពគណៈកម្មាធិការថ្នាក់ក្រោមជាតិ ជូន អភិបាលរាជធានី ខេត្តទាំង២៥ |
| ១៥:៥០-១៦:០០ | ការប្តេជ្ញាចិត្តរបស់អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស |
| ***កម្មវិធីទី៤: ពិធីប្រកាសផែនការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស*** | |
| ១៦:០០-១៦:១៥ | ពិធីប្រកាសផែនការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៤-២០១៨<br>-ខ្លឹមសារសង្ខេបនៃផែនការជាតិ ដោយ លោកជំទាវ ជូប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ |
| ១៦:១៥-១៦:២៥ | ចំណាប់អារម្មណ៍របស់តំណាង អង្គការ *USAID* |
| ១៦:២៥-១៦:៤០ | ពិធីប្រគល់ផែនការជាតិ ជូនប្រធានក្រុមការងារទាំង ៦<br>ដោយ **ឯកឧត្តម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ |
| ១៦:៤០-១៧:៣០ | ប្រសាសន៍ណែនាំ ដឹកនាំ ផ្តាំផ្ញើ និងបិទកម្មវិធី របស់ **ឯកឧត្តម ស ខេង** ឧបនាយក រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ |

*កម្មវិធីនេះ: អាចមានការកែប្រែតាមការចាំបាច់*

# មាតិកា

## ឯកសារ ក្នុងកិច្ចប្រជុំផ្សព្វផ្សាយ

| ល.រ | កម្មវិធី | ចំនួនច្បាប់ | ចំនួនសន្លឹក |
|---|---|---|---|
| ០១ | មតិស្វាគមន៍របស់លោកជំទាវ ជូ ប៊ុនអេង និងរបាយការណ៍សង្ខេបស្តីពីរចនាសម្ព័ន្ធនៃយន្តការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | ០១ | ០២ |
| ០២ | ព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>លេខនស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី០៤ខែកក្កដាឆ្នាំ២០១៤ | ០១ | ០៤ |
| ០៣ | សេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ<br>លេខ១៤៥សសរ ចុះថ្ងៃទី២២ខែតុលាឆ្នាំ២០១៤ | ០១ | ០៣ |
| ០៤ | អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស<br>លេខ២៧៣អនក្រ.បក ចុះថ្ងៃទី០៧ខែតុលាឆ្នាំ២០១៤ | ០១ | ០៣ |
| ០៥ | សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួងស្ថាប័នសម្រាប់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស<br>លេខ០០២/១៤សសរ ចុះថ្ងៃទី១៤ខែតុលាឆ្នាំ២០១៤ | ០១ | ០៦ |
| ០៦ | សេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ<br>លេខ០០១/១៤សសរ ចុះថ្ងៃទី១៤ខែតុលាឆ្នាំ២០១៤ | ០១ | ០៣ |
| ០៧ | ព្រះរាជក្រឹត្យ តែងតាំងឯកឧត្តម ឧត្តមសេនីយ៍ឯកចៅ ង សំអាត ជាអគ្គលេខាធិការ<br>លេខនស/រកត/១១១៤/១២៩៥ ចុះថ្ងៃទី០២ខែវិច្ឆិកាឆ្នាំ២០១៤ | ០១ | ០១ |
| ០៨ | អនុក្រឹត្យស្តីពីការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិ និងមន្ត្រីរាជការ<br>លេខ១៥១៨អនក្រ.តត ចុះថ្ងៃទី២៤ខែតុលាឆ្នាំ២០១៤ | ០១ | ០២ |
| ០៩ | អនុក្រឹត្យស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ<br>លេខ១៦៣៧.អនក្រ.តត ចុះថ្ងៃទី០៣ខែធ្នូឆ្នាំ២០១៤ | ០១ | ០១ |

| | | | |
|---|---|---|---|
| ១០ | អនុក្រឹត្យស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ និងមន្ត្រីនគរបាលជាតិកម្ពុជា<br>លេខ១៦៦០អនក្រ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៤ | ០១ | ០២ |
| ១១ | ខ្លឹមសារសង្ខេបនៃផែនការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០១៤-២០១៨ | ០១ | ០៦ |
| ១២ | មតិដឹកនាំ និងផ្តាំផ្ញើ បិទកម្មវិធី របស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ | ០១ | ០៣ |
| ១៣ | មតិចាប់អារម្មណ៍របស់ឯកឧត្តមឧត្តមសេនីយ៍ឯក ថោង សំអាត អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | ០១ | ០៣ |

-បានបញ្ចប់ត្រឹមលេខរៀងទី១៣ មានចំនួនច្បាប់១៣ច្បាប់ ចំនួនសន្លឹក៤០សន្លឹក។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# មតិស្វាគមន៍ និងរបាយការណ៍សង្ខេប

## ស្តីពី

## ការរៀបចំគណៈកម្មាធិការជាតិ និងរចនាសម្ព័ន្ធ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ដោយលោកជំទាវ ជូប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ
ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១៥

- សូមគោរពឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សូមគោរពឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ឯកឧត្តម នាយឧត្តមសេនីយ៍អគ្គស្នងការនគរបាលជាតិ អនុប្រធាន និង ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាទីគោរព
- ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត តំណាងស្ថានបេសកកម្មការទូត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការនៃបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ
- ឯកឧត្តម លោកជំទាវ អភិបាល អភិបាលរង អគ្គនាយក អគ្គនាយករង ឯកឧត្តមនាយឧត្តមសេនីយ៍ ឯក ឧត្តម លោកជំទាវឧត្តមសេនីយ៍ លោក លោកស្រី ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន លោកស្នងការ ស្នងការរង លោកលោកស្រី នាងកញ្ញា តំណាងអង្គការ សមាគមជាតិ និងអន្តរជាតិ ព្រមទាំង សមាជិកសមាជិកាទាំងអស់ នៃអង្គពិធីទាំងមូល ជាទីគោរពរាប់អាន

ថ្ងៃនេះ ក្នុងនាមសមាជិក សមាជិកាគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នាងខ្ញុំសូម សម្តែងនូវក្តីរំភើប និងសោមនស្សរីករាយ ជាអតិបរមា និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី គណៈអធិបតី ឯកឧត្តម លោកជំទាវជាភ្ញៀវកិត្តិយសជាតិ អន្តរជាតិ និងសមាជិក សមាជិកានៃអង្គពិធីទាំងអស់ ដែលបានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ អញ្ជើញចូលរួមក្នុងពិធីប្រកាសជាផ្លូវការ នូវគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) រចនាសម្ព័ន្ធថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងផែនការសកម្មជាតិ ប្រាំឆ្នាំ ២០១៤-២០១៨ នាថ្ងៃនេះ ។

ដូចឯកឧត្តម លោកជំទាវ លោក លោកស្រីបានជ្រាបហើយថា រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់វត្តមាននៃអំពើជួញដូរមនុស្សនៅកម្ពុជា និងផលប៉ះពាល់ទាំងឡាយនៃបទឧក្រិដ្ឋនេះ តាំងពីទសវត្សរ៍ឆ្នាំ៩០ និងបានកសាងច្បាប់សម្រាប់បង្ក្រាបបទល្មើសនេះតាំងពីឆ្នាំ១៩៩៦មកម្ល៉េះ ។ ចំពោះយន្តការសម្រាប់ការអនុវត្តន៍ បានចាប់ផ្តើមពីកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី នៅទីក្រុងយ៉ង់ហ្គូន សហភាពមីយ៉ាន់ម៉ា ឆ្នាំ២០០៤ ស្តីពីគំនិតផ្តួចផ្តើមសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងមហាអនុតំបន់ទន្លេមេគង្គដែលហៅថា ខមមីត ។ រាជរដ្ឋាភិបាល បានសម្រេចបង្កើតក្រុមការងារខមមីតកម្ពុជាក្នុងឆ្នាំ២០០៥ ដើម្បីអនុវត្តកិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងប្រាំមួយក្នុងមហាអនុតំបន់មេគង្គ ។ ក្នុងឆ្នាំ២០០៤នេះដែរ ក្រសួងមហាផ្ទៃ ក៏បានបង្កើតនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីទទួលបន្ទុកអនុវត្តច្បាប់និងបទដ្ឋានគតិយុទ្ធនានា ពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះ ជាពិសេស អនីតិជន ។

ឆ្នាំ២០០៧ មានក្រុមការងារថ្នាក់ជាតិមួយទៀត បង្កើតឡើងសម្រាប់អនុវត្តអនុស្សរណៈ និងកិច្ចព្រមព្រៀងទ្វេភាគីពហុភាគី ក្នុងគោលដៅប្រឆាំងអំពើជួញដូរមនុស្ស ។ ក្នុងឆ្នាំ២០០៧ដដែល មានក្រុមការងារថ្នាក់ជាតិមួយទៀត ដែលត្រូវបានបង្កើតឡើង សម្រាប់ដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ បន្ទាប់ពីមានករណីជួញដូរផ្លូវភេទធំមួយនៅរាជធានីភ្នំពេញ ដែលត្រូវការការបង្ក្រាបឲ្យមានប្រសិទ្ធភាព ។

ដូច្នេះ ក្នុងអំឡុងពេលនោះ យើងមានក្រុមការងារថ្នាក់ជាតិចំនួនបី ដែលធ្វើកិច្ចការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតែមួយ និងមានសមាសភាពចូលរួមប្រហាក់ប្រហែលគ្នា ។ ក្នុងឆ្នាំ២០០៨ ច្បាប់ថ្មីស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទ ត្រូវបានអនុម័ត ដោយអនុលោមតាម ពិធីសារអង្គការសហប្រជាជាតិ ស្តីពី ការទប់ស្កាត់ការបង្ក្រាប និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនមានអង្គការចាត់តាំង ដែលព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារ តាមព្រះរាជក្រមលេខនស/រកម/០១០៦/០០៤ចុះថ្ងៃទី១៨ខែមករាឆ្នាំ២០០៦ ។ ដូច្នេះចាំបាច់ រាជរដ្ឋាភិបាលកម្ពុជាត្រូវរៀបចំយន្តការឲ្យបានជាក់លាក់ ច្បាស់លាស់ ដើម្បីទទួលខុសត្រូវអនុវត្តច្បាប់ និងបទដ្ឋានជាតិ និងអន្តរជាតិទាំងនេះឲ្យមានប្រសិទ្ធភាព ។ ទន្ទឹមនឹងនោះ តាមបណ្តាក្រសួងស្ថាប័នមួយចំនួន ក៏បានបង្កើតអង្គភាព នាយកដ្ឋាន ឬការិយាល័យទទួលបន្ទុកការងារប្រឆាំងការជួញដូរមនុស្សដែរ ដូចជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងកិច្ចការនារី កងរាជអាវុធហត្ថជាដើម ។ ចំណែកឯអង្គការមិនមែនរដ្ឋាភិបាល ជាតិ និងអន្តរជាតិជាច្រើន បានតែធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សពាសពេញព្រះរាជាណាចក្រកម្ពុជា ។ ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងយ៉ាងនេះក្តី ក៏លទ្ធផលដែលទទួលបាន មិនទាន់បានល្អប្រសើរ ហើយអំពើជួញដូរមនុស្ស ក៏មានការវិវត្តន៍ និងបត់បែនប្រកបដោយល្បិចកល ដែលចាំបាច់ត្រូវរួមសហការគ្នា ប្រមូលផ្តុំគ្រប់កិច្ចខិតខំប្រឹងប្រែងនិងធនធានគ្រប់ផ្នែកដោះស្រាយបញ្ហា វាយឲ្យចំគោលដៅព្រមៗគ្នា ដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាប ជួយជនរងគ្រោះ និងផ្តន្ទាទោសជនល្មើសឲ្យមានប្រសិទ្ធភាពល្អប្រសើរនិងទាន់ពេលវេលា ។

នេះជាមូលហេតុនៃការរៀបចំឲ្យមានគណៈកម្មាធិការជាតិ តែមួយ ។

ដូច្នេះ នៅខែកញ្ញា ឆ្នាំ២០០៩ រាជរដ្ឋាភិបាលបាន ដាក់ចេញនូវអនុក្រឹត្យ លេខ ១៦២ អនក្រ.បក ចុះថ្ងៃទី២៥ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីបង្កើតគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាប អំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ (ប.ជ.រ.ព.ភ) ដែលមានក្រសួង ស្ថាប័ន និងអង្គភាពចំនួន ១៤ ចូលរួមជាសមាជិក មានលេខាធិការដ្ឋានអន្តរក្រសួងមួយ ដែលចែកចេញជា០៧ក្រុមការងារ អន្តរក្រសួង ស្ថាប័ន។ គណៈកម្មាធិការជាតិនេះ មានតួនាទី អនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និង ផែនការសកម្មភាពជាតិ ប.ជ.រ.ភ.ព ឆ្នាំ២០១១-២០១៣ ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយគណៈកម្មាធិការជាតិ ក្នុងឆ្នាំ២០១១ ។

ឆ្នាំ២០១៣ ជាឆ្នាំបញ្ចប់នៃការអនុវត្តផែនការសកម្មភាពជាតិ ហើយក៏ជាឆ្នាំបញ្ចប់អណត្តិនៃរាជរដ្ឋាភិបាល នីតិកាលទី៤ នៃរដ្ឋសភាដែរ ដែលក្នុងតំណាក់កាលនេះ មានការផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការជាតិ និងសភាពការណ៍ជាច្រើន ។ បន្ទាប់ពីមានការវាយតម្លៃលើលទ្ធផលនៃការអនុវត្តផែនការសកម្មភាពជាតិទី១ ឆ្នាំ២០១១-២០១៣ រួចមក ជាលទ្ធផល គឺបានរកឃើញនូវចំណុចខ្វះខាតមួយចំនួនក្នុងការអនុវត្ត និងកំណត់យ៉ាងជាក់លាក់នូវទិសដៅដែលត្រូវបន្ត ។ ក្នុងនោះ ការរៀបចំឡើងវិញនូវគណៈកម្មាធិការជាតិ ដោយកែសម្រួលតួនាទីភារកិច្ច តាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ គឺជាកិច្ចការមួយចាំបាច់បន្ទាន់ ។ ដំណើរការនៃការរៀបចំនេះ ត្រូវបានចាប់ផ្តើម ដោយមានការសម្រេចជាផ្លូវការដោយគណៈកម្មាធិការជាតិ ក្នុងកិច្ចប្រជុំ ដែលប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៣ ថាត្រូវរៀបចំគណៈកម្មាធិការជាតិជាថ្មី និងកំណត់ឲ្យលេខាធិការដ្ឋានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ កំណត់តួនាទី ភារកិច្ច រចនាសម្ព័ន្ធ សមាសភាព គណៈកម្មាធិការជាតិ អនុក្រឹត្យ សេចក្តីសម្រេច និងបទដ្ឋានពាក់ព័ន្ធដទៃទៀតជាច្រើន ។ សេចក្តីព្រាងទាំងអស់នេះ ត្រូវបានដាក់ស្នើសុំយោបល់ ដោយមានការចូលរួមកែលម្អជាច្រើនលើកច្រើនសារពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ជាតិ និងអន្តរជាតិ រហូតបានសម្រេចជាស្ថាពរ ។

គណៈកម្មាធិការជាតិដែលត្រូវបានបង្កើតឡើងជាថ្មីនេះ ឈ្មោះថា **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)** ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ លេខ នស/រកត/០៦១៤/៨០ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៤ ដែលមានក្រសួងចំនួន ២២ និងអង្គភាពជំនាញចំនួន០៤ ជាសមាជិក ចែកចេញជាក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន ចំនួន០៦ និងមានរចនាសម្ព័ន្ធដល់ថ្នាក់ក្រោមជាតិ ដែលជាគណៈកម្មាធិការរាជធានីខេត្ត ទាំង២៥ និងមានមន្ត្រីទទួលបន្ទុកសម្របសម្រួល និងជម្រុញការអនុវត្តន៍ នៅថ្នាក់ក្រុង ស្រុក ខណ្ឌ រហូតដល់មូលដ្ឋាន ឃុំ សង្កាត់ ទូទាំងព្រះរាជណាចក្រកម្ពុជា ។

គ.ជ.ប.ជ គឺជាយន្តការជាតិ ដែលមានតួទីសម្របសម្រួល ប្រមូលផ្តុំគ្រប់កិច្ចខិតខំប្រឹងប្រែង របស់គ្រប់ក្រសួងស្ថាប័ន គ្រប់ផ្នែក គ្រប់ថ្នាក់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងបើកទូលាយឲ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ផ្នែកឯកជន និងអ្នកពាក់ព័ន្ធទាំងឡាយ ដើម្បីរួមគ្នាបង្ការទប់ស្កាត់ បង្ក្រាប កាត់បន្ថយ ឈានទៅលុបបំបាត់រាល់ទម្រង់នៃការជួញដូរមនុស្ស និងការធ្វើអាជីវកម្ម កេងប្រវ័ញ្ចលើមនុស្ស គ្រប់រូបភាព ដែលកើតមានទាំងនៅក្នុង និងនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

គណៈកម្មាធិការជាតិ ក៏មានភារកិច្ចសិក្សាស្វែងយល់ និងតាមដានសភាពការណ៍វិវត្តន៍ប្រែប្រួល នៃបទល្មើស ដោយយកចិត្តទុកដាក់ជម្រុញ លើកកម្ពស់ការបង្ការទប់ស្កាត់ កិច្ចការពារជនរងគ្រោះទាំងកុមារ យុវវ័យ ស្ត្រី និងបុរស លើកកម្ពស់ការអនុវត្តច្បាប់ដើម្បីបង្ក្រាប សង្គ្រោះ និងផ្តន្ទាទោស និងការពង្រឹងនូវកិច្ចសហប្រតិបត្តិការ និងការចូលរួមគាំទ្រអនុវត្តពីគ្រប់ភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិយ៉ាងទូលំទូលាយ ។

អគ្គលេខាធិការដ្ឋានមួយ ត្រូវបានបង្កើតឡើងដើម្បីធ្វើជាសេនាធិការជូនគណៈកម្មាធិការជាតិ ក្នុងកិច្ចប្រតិបត្តិការប្រចាំថ្ងៃ សិក្សាស្រាវជ្រាវ ពង្រឹងកិច្ចសហការ ជម្រុញ តាមដានត្រួតពិនិត្យសភាពការណ៍ប្រែប្រួលនៃបទល្មើស ប្រមូលគ្រប់ព័ត៌មាន ទិន្នន័យ ដែលពាក់ព័ន្ធ និងធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិ និងរាជរដ្ឋាភិបាល បានជ្រាប និងមានវិធានការតាមការចាំបាច់ ព្រមទាំងអប់រំផ្សព្វផ្សាយដល់សាធារណជន ។

ក្រុមការងារ ប្រាំមួយ ត្រូវបានបង្កើតឡើង ជាក្រុមការងារជំនាញអន្តរក្រសួងស្ថាប័ន គឺៈ

១. ក្រុមការងារបង្ការ និងទប់ស្កាត់ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា

២. ក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៣. ក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយអគ្គស្នងការនគរបាលជាតិ

៤. ក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយ ក្រសួងយុត្តិធម៌

៥. ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយក្រសួងកិច្ចការនារី

៦. ក្រុមការងារទេសន្តរប្រវេសន៍ ដឹកនាំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ដែលក្រុមការងារទាំង០៦ មានការទទួលខុសត្រូវចំពោះគណៈកម្មាធិការជាតិ តាមមុខសញ្ញារៀងៗខ្លួន និងពង្រីកការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើប្រជាពលរដ្ឋជាក្រុមគោលដៅ ទាំង បុរស ស្ត្រី យុវវ័យ និងកុមារ ។

ថ្ងៃនេះ គណៈអធិបតី និងអង្គពិធីទាំងមូល នឹងបានចូលរួមក្នុងពិធីប្រកបដោយកិត្តិយស នៃការប្រកាសជាផ្លូវការនូវយន្តការជាតិនេះ ព្រមទាំង សមាសភាព រចនាសម្ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលនឹងត្រូវទទួលអនុវត្តភារកិច្ចឲ្យមានប្រសិទ្ធភាពក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា ។

ជាថ្មីម្តងទៀត ក្នុងនាមសមាជិកាសមាជិកានៃគណៈកម្មាធិការជាតិ គណៈកម្មាធិការថ្នាក់ក្រោមជាតិ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋានរាជធានី ខេត្ត ខ្ញុំសូមគោរពថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឯកឧត្តម លោកជំទាវរដ្ឋមន្ត្រីជាគណៈអធិបតី អង្គទូតនានា ឯកឧត្តម លោកជំទាវភ្ញៀវជាតិ និងអន្តរជាតិ សមាជិកសមាជិកានៃអង្គពិធីទាំងមូល ដែលបានឆ្លៀតឱកាសដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងពិធីប្រកាសជាផ្លូវការគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រចនាសម្ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងផែនការសកម្មភាពជាតិ ៥ឆ្នាំ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ២០១៤-២០១៨នាថ្ងៃនេះ និងសូមគោរពជូនពរសូមទេវតាឆ្នាំថ្មី ប្រសិទ្ធិពរជ័យ សិរីសួស្តី បវរមហាប្រសើរ និង វិបុលសុខគ្រប់ប្រការជូនឯកឧត្តម លោកជំទាវ លោក លោកស្រី ក្រុមគ្រួសារ និងបងប្អូនជនរួមជាតិ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអរគុណ

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៤/៨០៩

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិ
## ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១០៦/០០៤ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារស្តីពីការទប់ស្កាត់ ការបង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០២០៨/០០៥ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានបង្កើត គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលសរសេរជាអក្សរកាត់ថា គ.ជ.ប.ជ ។

## ជំពូកទី២
## សមាសភាព គ.ជ.ប.ជ

មាត្រា ២.-

គ.ជ.ប.ជ មានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | | ប្រធាន |
| ២. រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | អនុប្រធាន |
| ៣. រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | | អនុប្រធាន |
| ៤. រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | | អនុប្រធាន |
| ៥. រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | អនុប្រធាន |
| ៦. រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា | | អនុប្រធាន |
| ៧. រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៨. អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ | | អនុប្រធាន |
| ៩. រដ្ឋលេខាធិការក្រសួងសុខាភិបាល | ១រូប | សមាជិក |
| ១០. រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| ១១. រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | សមាជិក |
| ១២. រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ១រូប | សមាជិក |
| ១៣. រដ្ឋលេខាធិការក្រសួងការពារជាតិ | ១រូប | សមាជិក |
| ១៤. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១រូប | សមាជិក |
| ១៥. រដ្ឋលេខាធិការក្រសួងផែនការ | ១រូប | សមាជិក |
| ១៦. រដ្ឋលេខាធិការក្រសួងព័ត៌មាន | ១រូប | សមាជិក |
| ១៧. រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ១រូប | សមាជិក |

១៨. រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ ១រូប សមាជិក
១៩. រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ១រូប សមាជិក
២០. រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម ១រូប សមាជិក
២១. រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ១រូប សមាជិក
២២. រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ១រូប សមាជិក
២៣. រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ១រូប សមាជិក
២៤. មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
២៥. អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃ សមាជិក
២៦. អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ សមាជិក
២៧. នាយកកិច្ចការព្រំដែននៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ សមាជិក

សមាសភាពជាក់ស្តែងនៃគ.ជ.ប.ជត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទី និងភារកិច្ចរបស់ គ.ជ.ប.ជ

**មាត្រា៣.-**

គ.ជ.ប.ជ គឺជាយន្តការអន្តរស្ថាប័នថ្នាក់ជាតិ ដែលមានតួនាទីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាល ក្នុងការដឹកនាំ សម្របសម្រួលប្រមូលផ្តុំការចូលរួមកិច្ចសហការ និងការគាំទ្រពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការសហប្រជាជាតិ អង្គការដៃគូជាតិ អន្តរជាតិ ផ្នែកឯកជនរួមទាំងយន្តការក្នុងតំបន់ និងបណ្តាប្រទេសពាក់ព័ន្ធទាំងឡាយ សម្រាប់ការងារប្រយុទ្ធប្រឆាំងនឹងរាល់ទម្រង់នៃអំពើជួញដូរ និងអំពើធ្វើអាជីវកម្មកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាព ជាពិសេសលើស្ត្រីនិងកុមារ ដែលកើតមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

គ.ជ.ប.ជ មានភារកិច្ចដូចខាងក្រោម៖

១. ជម្រុញនិងលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពិធីសារស្តីពីការទប់ស្កាត់ការបង្ក្រាបនិងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ឬលិខិតតុបករណ៍ និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀតទាក់ទងនឹងអំពើជួញដូរមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិកហត្ថលេខី។

២. ជម្រុញនិងពង្រឹងការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

៣. ជម្រុញនិងពង្រឹងកិច្ចការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅតាមគ្រប់តំណាក់កាលនៃនីតិវិធីតុលាការ។

៤. ជម្រុញ និងតាមដានការអនុវត្តច្បាប់ គោលនយោបាយជាតិ អន្តរជាតិពាក់ព័ន្ធ និងគោលការណ៍ណែនាំផ្សេងៗរបស់រាជរដ្ឋាភិបាល ព្រមទាំងគាំទ្រឲ្យមានការចុះហត្ថលេខា ឬការផ្តល់សច្ចាប័នលើលិខិតគុបករណ៍អន្តរជាតិទាំងឡាយណាដែលមានសារៈប្រយោជន៍ដល់ការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស។

៥. តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសភាពការណ៍ប្រែប្រួលនៃបទល្មើសជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងបទល្មើសពាក់ព័ន្ធដទៃទៀត ដោយយកចិត្តទុកដាក់លើភាពរងគ្រោះរបស់ប្រជាពលរដ្ឋ ទាំងស្ត្រី បុរស ជាពិសេសកុមារ និងយុវវ័យ។

៦. ពិនិត្យកែលំអ និងស្នើឲ្យក្រសួង ស្ថាប័នពាក់ព័ន្ធរៀបចំតាក់តែងបំពេញបន្ថែម នូវអត្ថបទច្បាប់ បទដ្ឋានគតិយុត្តិដែលនៅខ្វះខាត ដាក់ចេញគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពដើម្បីបង្ការទប់ស្កាត់បទល្មើស ជួយសង្គ្រោះ និងការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សគ្រប់រូបភាពនិងជម្រុញការផ្សព្វផ្សាយអប់រំឲ្យបានទូលំទូលាយដល់សាធារណៈជន បានយល់ដឹងនិងចូលរួមអនុវត្ត ។

៧. ជម្រុញឲ្យមានមជ្ឈមណ្ឌលគាំ ដែលអនុវត្តតាមបទដ្ឋានបានត្រឹមត្រូវ សម្រាប់ការស្តារនីតិសម្បទាជនរងគ្រោះមាតុភូមិនិវត្តន៍ មុននឹងធ្វើសមាហរណកម្មទៅគ្រួសារ ឬសហគមន៍ វិញ ។

៨. ជម្រុញនិងលើកកម្ពស់ការទទួលខុសត្រូវរបស់ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឲ្យឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សមានជាអាទិ៍៖ ពង្រឹងការអនុវត្តច្បាប់ ការលុបបំបាត់និទណ្ឌភាព ការស៊ើបអង្កេត និងការផ្តន្ទាទោសជនល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដើម្បីលើកកម្ពស់ការជឿទុកចិត្តពីប្រជាពលរដ្ឋ ជាពិសេសពីជនរងគ្រោះលើប្រព័ន្ធយុត្តិធម៌ សេវាសង្គម សេវាសាធារណៈ និងចូលរួមអនុវត្តច្បាប់។

៩. ពង្រឹងនិងពង្រីកទំនាក់ទំនងកិច្ចសហប្រតិបត្តិការនិងការគាំទ្រពីបណ្តាអង្គការដៃគូជាតិ អន្តរជាតិ ទីភ្នាក់ងារសហប្រជាជាតិនិងជាមួយប្រទេសពាក់ព័ន្ធនានាដើម្បីការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

១០. ពិនិត្យសម្រេច និងផ្សព្វផ្សាយផែនការជាតិ និងរបាយការណ៍ជាតិ ស្តីពីសកម្មភាព និងលទ្ធផលនៃការងារប្រឆាំងការជួញដូរមនុស្ស។

ROYAUME DU CAMBODGE
MINISTERE DU PALAIS ROYAL

១១. រៀបចំរបាយការណ៍ស្ដីពីស្ថានភាពនិងការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទជូនរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិតាមការកំណត់។

១២. ពិនិត្យ អនុម័ត និងគ្រប់គ្រងគម្រោងថវិកាប្រចាំឆ្នាំរបស់ គ.ជ.ម.ជ។

១៣. អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

មាត្រា ៥.-

គ.ជ.ម.ជ ត្រូវរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ខ្លួនជាទៀងទាត់ប្រចាំត្រីមាស។ ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំវិសាមញ្ញបាន។

របៀបរបបការងារនិងកិច្ចដំណើរការប្រជុំរបស់គ.ជ.ម.ជ ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង។

មាត្រា ៦.-

ប្រធានគ.ជ.ម.ជ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន មន្ត្រីជំនាញ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនានា ឲ្យចូលរួមប្រជុំពិគ្រោះយោបល់ និងបំភ្លឺលើរាល់បញ្ហាទាំងឡាយដែលទាក់ទងនឹងក្របខ័ណ្ឌការងារគ.ជ.ម.ជ។

មាត្រា ៧.-

គ.ជ.ម.ជ មានរូបសញ្ញាសម្គាល់ និងត្រាដោយឡែករបស់ខ្លួន។

គំរូត្រានិងខ្លឹមសាររូបសញ្ញាសម្គាល់របស់ គ.ជ.ម.ជ មានភ្ជាប់ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។

មាត្រា ៨.-

គ.ជ.ម.ជ មានអគ្គលេខាធិការដ្ឋានមួយជាអង្គភាពប្រតិបត្តិ ដែលមានទីតាំងនៅក្នុងមូលដ្ឋានណាមួយនៃទីស្ដីការក្រសួងមហាផ្ទៃ និងមានមន្ត្រីបំរើការងារជាក្របខ័ណ្ឌក្រសួងមហាផ្ទៃ។

អនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.ម.ជ ត្រូវបានប្រគល់ភារកិច្ចឲ្យទទួលបន្ទុក អគ្គលេខាធិការដ្ឋានដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ម.ជ ត្រូវកំណត់ដោយអនុក្រឹត្យ។

មាត្រា ៩.-

គ.ជ.ម.ជ អាចទទួលយកនិងតែងតាំងទីប្រឹក្សាបច្ចេកទេស អ្នកជំនាញជាតិ អន្តរជាតិមួយចំនួនតាមការចាំបាច់ ដើម្បីជួយការងារ គ.ជ.ម.ជ និងអគ្គលេខាធិការដ្ឋាន។

មាត្រា ១០.-

គ.ជ.ម.ជ ត្រូវបង្កើតក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន មួយចំនួនតាមការចាំបាច់។ សមាសភាព តួនាទី និងភារកិច្ចជាក់ស្តែងរបស់ក្រុមការងារជំនាញនីមួយៗត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ជ.ម.ជ។

មាត្រា ១១.-

គ.ជ.ម.ជ ត្រូវបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ ដែលគណៈកម្មាធិការខេត្តសរសេរអក្សរកាត់ថា គ.ខ.ម.ជ និងគណៈកម្មាធិការរាជធានីសរសេរអក្សរកាត់ថា គ.រ.ម.ជ ។

សមាសភាព តួនាទី និងភារកិច្ច និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន គ.ជ.ម.ជ ។

## ជំពូកទី៤
## ប្រភពធនធាន

មាត្រា ១២.-

គ.ជ.ម.ជ មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិដែលជាកញ្ចប់ថវិកាដោយឡែក នៅក្នុងឧបសម្ព័ន្ធនៃកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ ។ ចំពោះថវិកាសម្រាប់ការងារប្រយុទ្ធប្រឆាំងការជួញដូរមនុស្សរបស់ គ.រ.ម.ជ និង គ.ខ.ម.ជ នីមួយៗ គឺជាថវិកាឧបសម្ព័ន្ធរបស់រាជធានី-ខេត្ត នោះ ។

គ.ជ.ម.ជ មានសិទ្ធិទទួល គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងប្រភពផ្សេងៗទៀតដើម្បីធានាការអនុវត្តដំណើរការការងាររបស់ខ្លួន ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

មាត្រា ១៣.-

អនុក្រឹត្យលេខ ១៦២អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិដឹកនាំ ម.ជ.រ.ព.ភ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE * PALAIS ROYAL *

មាត្រា ១៤.-

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៧.១៤០៦.៥២២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

បានចុះលេខ ... ០ ស.ណ

សំណៅដែលមានតម្លៃជាការចេញផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ មិថុនា ឆ្នាំ២០១៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊យ សុខា

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១៤៥ សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣ /៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## សម្រេច

ប្រការ១-

ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដូចមានរាយនាមខាងក្រោម ៖

| | | |
|---|---|---|
| ១.ឯកឧត្ដម ស ខេង | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២.ឯកឧត្ដម អ៊ិត សំហេង | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣.លោកជំទាវ អ៊ឹង កន្ថាផាវី | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | អនុប្រធាន |
| ៤.ឯកឧត្ដម អង្គ វង្សវឌ្ឍានា | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |

| | | |
|---|---|---|
| ៥.ឯកឧត្តម ខង សុខ | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៦.ឯកឧត្តម ហង់ ជួនណារ៉ុន | រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៧.លោកជំទាវ ង៉ុ ម៉ុនអេង | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធានអចិន្ត្រៃយ៍ |
| ៨.ឯកឧត្តម នាយឧត្តមសេនីយ៍ | នេត សាវឿន អគ្គស្នងការ នគរបាលជាតិ | អនុប្រធាន |
| ៩.ឯកឧត្តម ស៊ូ គីរិន្ទ | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១០.ឯកឧត្តម ឡុង វិសាលោ | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១១.លោកជំទាវ ដាំ ដាវីនី | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១២.ឯកឧត្តម ង៉ូ ទិជិត្ត | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៣.លោកជំទាវ ម៉ែន សុបតា | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ១៤.ឯកឧត្តម ថៃ នរៈសត្យា | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៥.លោកជំទាវ ម៉ាត់ ម៉ារ៉ា | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៦.លោកជំទាវ ចាន់ ធី | រដ្ឋលេខាធិការក្រសួងព័ត៌មាន | សមាជិក |
| ១៧.លោកជំទាវ នួច សារ៉ុម | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | សមាជិក |
| ១៨.លោកជំទាវ វ៉ាន់ ម៉ារា | រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៩.លោកជំទាវ តាន់ ខូចឆេង | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ២០.លោកជំទាវ ប្រាក់ ច័ន្ទណាយ | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២១.លោកជំទាវ ហោ ម៉ាលីន | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២២.លោកជំទាវ ឡាយ ណាទីន | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ២៣.ឯកឧត្តម ហោ សារុន | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ២៤.ឯកឧត្តម នាយឧត្តមសេនីយ៍ | សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ២៥.ឯកឧត្តម នាយឧត្តមសេនីយ៍ | ម៉ៅ ច័ន្ទតារា អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ | សមាជិក |
| ២៦.ឯកឧត្តម នាយឧត្តមសេនីយ៍ | សុខ ផល អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| ២៧.ឯកឧត្តម ឧត្តមសេនីយ៍ឯក | សៀក សុជាតិ នាយកទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ | សមាជិក |

ប្រការ២-

ក្នុងករណីដែលក្រសួងស្ថាប័ន ឬអង្គភាពណាមួយមានការផ្លាស់ប្តូរសមាសភាពខាងលើ ត្រូវធ្វើសំណើមកប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីតែងតាំងជាថ្មី។

ប្រការ៣-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងសេចក្តីសម្រេចនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន អង្គភាព និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តតាមសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ តុលា.....ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

*__កន្លែងទទួល__*

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-អគ្គលេខាធិការរាជរដ្ឋាភិបាល*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*

*-ដូចប្រការ១*

*-រាជកិច្ច*

*-ឯកសារ*

*-កាលប្បវត្តិ*

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៧៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៦/០០៤ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃពិធីសារស្តីពីការទប់ស្កាត់បង្ក្រាប និងដាក់ទណ្ឌកម្មអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋឆ្លងដែន ដែលមានអង្គការចាត់តាំង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

អនុក្រឹត្យនេះ មានគោលបំណងកំណត់តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងការសម្របសម្រួលការងារដែលពាក់ព័ន្ធជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិ នឹងជាមួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ រាជធានី ខេត្ត ក្នុងការប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាព ជាពិសេសលើស្ត្រី និងកុមារ ។

**មាត្រា ២.–**

អនុក្រឹត្យនេះ មានគោលដៅលើកកម្ពស់ប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ការងារដឹកនាំ គ្រប់គ្រង និងជួយជំរុញការអនុវត្តច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ព្រមទាំងពិធីសារស្តីពីការទប់ស្កាត់ ការបង្រ្កាបនិងការដាក់ទណ្ឌកម្ម អំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំង និងឧក្រិដ្ឋកម្មឆ្លងដែន និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀត ទាក់ទងនិងអំពើជួញដូរមនុស្ស ដែលព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័ន ។

## ជំពូកទី ២

## តួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ

**មាត្រា ៣.–**

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ មានតួនាទីជាអង្គភាពប្រតិបត្តិធ្វើជាសេនាធិការជូនគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស គ.ជ.ប.ជ ដោយមានភារកិច្ច ដូចខាងក្រោម ៖

- សម្របសម្រួលការងារជាមួយក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន នៃ គ.ជ.ប.ជ ដូចមានចែងក្នុងមាត្រា ១០ នៃព្រះរាជក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- សហការជាមួយគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី (គ.រ.ប.ជ) និងគណៈ-កម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត (គ.ខ.ប.ជ)
- សហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិពាក់ព័ន្ធ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- តាមការប្រគល់សិទ្ធិពីប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ ធ្វើទំនាក់ទំនងជាមួយ ស្ថានទូត ស្ថានតំណាង និងរដ្ឋាភិបាលនៃប្រទេសពាក់ព័ន្ធនានា ដើម្បីស្នើសុំឱ្យមានការស្រាវជ្រាវអំពីករណី ឬភាពមិនប្រក្រតី និងផលប៉ះពាល់នៃបទល្មើសជួញដូរមនុស្ស
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃសភាពការណ៍ប្រែប្រួលនៃបទល្មើសជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងបទល្មើសពាក់ព័ន្ធដទៃទៀត ដោយយកចិត្តទុកដាក់លើភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋទាំងស្ត្រី ទាំងបុរស ជាពិសេសកុមារ និងយុវវ័យ
- សហការជាមួយសមត្ថកិច្ចជំនាញ ដើម្បីលើកសំណើបណ្តុះបណ្តាលធនធានមនុស្ស និងអភិវឌ្ឍន៍សមត្ថភាព ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស
- រៀបចំផ្សព្វផ្សាយផែនការសកម្មភាពរយៈពេលវែង មធ្យម និងរយៈពេលខ្លីរបស់ គ.ជ.ប.ជ ដើម្បីឱ្យស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋយល់ជ្រួតជ្រាបអំពីការប្រឆាំងនឹងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ

-តាមការប្រគល់សិទ្ធិពីប្រធាន គ.ជ.ប.ជ ដើម្បីរៀបចំ និងចូលរួមកិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ចសិក្សា និងសន្និសីទផ្សេងៗទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងជាមួយអន្តរជាតិ ពាក់ព័ន្ធការងារប្រឆាំងអំពើជួញដូរមនុស្ស

-លើកគម្រោងផែនការថវិកា ភស្តុភារ សម្ភារបច្ចេកទេស និងមធ្យោបាយស្របតាមច្បាប់ស្តីពីហិរញ្ញវត្ថុ

-កៀរគរធនធានថវិកា សម្ភារ មធ្យោបាយ និងការចូលរួមគាំទ្រពីបណ្តាដៃគូពាក់ព័ន្ធនានា

-ទទួលបានការប្រគល់សិទ្ធិពីប្រធាន គ.ជ.ប.ជ គ្រប់គ្រង និងចាត់ចែង ថវិកា សម្ភារ បរិក្ខារ មធ្យោបាយ និងការងារពាក់ព័ន្ធរបស់ គ.ជ.ប.ជ ដូចមានចែងក្នុងមាត្រា ១២ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

-ដឹកនាំគ្រប់គ្រងមន្ត្រីអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ លើកសំណើតែងតាំង ដំឡើងឋានៈ ឬផ្លាស់ប្តូរភារកិច្ច លើកសរសើរ អនុវត្តវិន័យដល់មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដាក់ជូនអនុប្រធានអចិន្ត្រៃយ៍ នៃ គ.ជ.ប.ជ ពិនិត្យសម្រេច មុននឹងសុំសេចក្តីសម្រេចពីប្រធាន គ.ជ.ប.ជ.

-គ្រប់គ្រង ទុកដាក់ បែងចែក ឯកសារ និងលិខិតចេញ-ចូល របស់អគ្គលេខាធិការដ្ឋាន នៃ គ.ជ.ប.ជ.

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែជូនប្រធានគណៈកម្មាធិការជាតិ គ.ជ.ប.ជ.

- រៀបចំសេចក្តីព្រាងរបាយការណ៍លទ្ធផលការងារប្រចាំត្រីមាស ឆមាស និងឆ្នាំ និងទិសដៅបន្តដាក់ជូនប្រធានគណៈកម្មការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពិនិត្យសម្រេច

-រៀបចំខ្លឹមសារសម្រាប់កិច្ចប្រជុំនានា របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ.

-ប្រមូល ចងក្រងបោះពុម្ព និងផ្សព្វផ្សាយរបាយការណ៍ខែ ត្រីមាស ឆមាស និងឆ្នាំរបស់ គ.ជ.ប.ជ.

-បំពេញភារកិច្ចផ្សេងៗទៀត ដែលប្រធាន គ.ជ.ប.ជ និងក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

**មាត្រា ៤._**

អគ្គលេខាធិការដ្ឋាន មានសិទ្ធិប្រើប្រាស់ត្រា និងរូបសញ្ញាសម្គាល់របស់ គ.ជ.ប.ជ ។

**មាត្រា ៥._**

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ ដឹកនាំដោយអគ្គលេខាធិការ មួយរូប និងមានអគ្គលេខាធិការរង មួយចំនួន តាមការចាំបាច់

-អគ្គលេខាធិការ អគ្គលេខាធិការរង ត្រូវតែងតាំងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ។

**មាត្រា ៦._**

អគ្គលេខាធិការដ្ឋាន នៃ គ.ជ.ប.ជ បង្កើតឱ្យមានលេខាធិការដ្ឋានរដ្ឋបាល សរុប មួយ សម្រាប់ដំណើរការលើការងារឱ្យមានប្រសិទ្ធភាព ។

**មាត្រា ៧._**

អគ្គលេខាធិការដ្ឋាន នៃ គ.ជ.ប.ជ មានរចនាសម្ព័ន្ធ ដូចខាងក្រោម ៖

- លេខាធិការដ្ឋានរដ្ឋបាល សរុប
- ក្រុមមន្ត្រីជំនួយការ អគ្គលេខាធិការដ្ឋាន

លេខាធិការដ្ឋានរដ្ឋបាល សរុប ដឹកនាំដោយប្រធាន មួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានលេខាធិការដ្ឋាន ជាជំនួយការ មានឋានៈ និងបុព្វសិទ្ធិស្មើអនុប្រធាននាយកដ្ឋាន ចំណុះក្រសួងមហាផ្ទៃ.៤/

ក្រុមមន្ត្រីជំនួយការរបស់អគ្គលេខាធិការដ្ឋាន មានចំនួនសមស្រប តាមទំហំក្រុមការងារជំនាញនីមួយៗ សម្រាប់ទំនាក់ទំនងការងារជាមួយក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន ដែលមានឋានៈ និងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន ឬអនុប្រធាននាយកដ្ឋាន

មន្ត្រីដែលបម្រើការងារក្នុងអគ្គលេខាធិការដ្ឋាន លេខាធិការដ្ឋាន និងក្រុមមន្ត្រីជំនួយការ ត្រូវមានក្របខ័ណ្ឌមកពីក្រសួងមហាផ្ទៃ ។ ក្នុងករណីចាំបាច់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ អាចស្នើសុំមន្ត្រីជំនាញពីក្រសួងដទៃ ។

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋានរដ្ឋបាល សរុប និងក្រុមមន្ត្រីជំនួយការ ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន គ.ជ.ប.ជ ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

សេចក្តីសម្រេចលេខ ៩២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋាន "ប.ជ.រ.ព.ភ" និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនៃអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ប្រធានស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**
**សូមហត្ថលេខា**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងប្រធាន គ.ជ.ប.ជ**

**ស ខេង**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# អង្គការលេខ របស់គណៈកម្មាធិការជាតិ
# ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង

អំពើជួញដូរមនុស្ស

គ.ជ.ប.ជ

លេខៈ ០០៧/...ស.គ.ន...

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ខែកញ្ញាឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នីតិកាលទី៥នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទចុះថ្ងៃទី១៥ខែកុម្ភៈឆ្នាំ២០០៨
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៦១៤/៨០៨ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញអនុក្រឹត្យលេខ២៧៣អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន ចំនួន០៦ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាយន្តការសម្របសម្រួលការងារដឹកនាំ និងអនុវត្ត ដើម្បីធានាឱ្យមានកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាល ផ្នែកឯកជន វិទ្យាស្ថានឬអ្នកស្រាវជ្រាវ អង្គការដៃគូជាតិ អន្តរជាតិ និងអ្នកពាក់ព័ន្ធដទៃទៀត ធ្វើឲ្យសម្រេចផែនការជាតិ និងយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

**ប្រការ២.-**

ក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័នទាំង០៦គឺៈ

១. ក្រុមការងារបង្ការ ទប់ស្កាត់

២. ក្រុមការងារការពារជនរងគ្រោះ

៣. ក្រុមការងារអនុវត្តច្បាប់

៤. ក្រុមការងារកិច្ចការយុត្តិធម៌

៥. ក្រុមការងារកិច្ចការទេសន្តរប្រវេសន៍

៦. ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ។

**ប្រការ ៣.-**

ក្រុមការងារបង្ការ ទប់ស្កាត់ ដឹកនាំដោយក្រសួងអប់រំយុវជន និងកីឡា និងមានសមាសភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ដែលបាននឹងកំពុងធ្វើសកម្មភាពក្នុងគោលដៅបង្ការទប់ស្កាត់អំពើជួញដូរមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក. សមាសភាព៖

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា | អនុប្រធានអចិន្ត្រៃយ៍ |
| - តំណាងក្រសួងកិច្ចការនារី | អនុប្រធាន |
| - តំណាងក្រសួងទេសចរណ៍ | អនុប្រធាន |
| - តំណាងអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ | អនុប្រធាន |
| - តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - អគ្គនាយកបច្ចេកទេស ឬអគ្គនាយករងក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| - តំណាងក្រសួងព័ត៌មាន | សមាជិក |
| - តំណាងក្រសួងវប្បធម៌ វិចិត្រសិល្បៈ | សមាជិក |
| - តំណាងក្រសួងធម្មការ សាសនា | សមាជិក |
| - តំណាងក្រសួងប្រៃសណីយ៍ ទូរគមនាគមន៍ | សមាជិក |
| - តំណាងក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - តំណាងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - តំណាងក្រសួងសុខាភិបាល | សមាជិក |
| - តំណាងក្រសួងកសិកម្ម | សមាជិក |
| - តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| - តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| - តំណាងទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ | សមាជិក |
| - តំណាងកាកបាទក្រហមកម្ពុជា | សមាជិក |
| - តំណាងសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ | សមាជិក |

- តំណាងសហភាពសហព័ន្ធយុវជន　　　　　　　　　　　សមាជិក
- តំណាងអង្គការដៃគូជាតិ និងអន្តរជាតិដទៃទៀត　　　　　សមាជិក

ខ. ភារកិច្ចៈ

ក្រុមការងារបង្ការទប់ស្កាត់មានភារកិច្ចដូចតទៅ ៖

- ពង្រឹងកិច្ចសហការរវាងសមាជិកក្នុងក្រុមការងារ ជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងដៃគូពាក់ព័ន្ធដទៃទៀត ដើម្បីៈ
    - ០ រៀបចំបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងថវិកាសម្រាប់ការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្សតាមគ្រប់រូបភាពនិងដាក់ជូន គ.ជ.ប.ជ ពិនិត្យ និងផ្តល់យោបល់
    - ០ បង្កើតសារ ឯកសារអប់រំ និងវិធីសាស្ត្រថ្មីៗសម្រាប់អប់រំយុវវ័យអំពីជំរើសត្រឹមត្រូវដើម្បីអនាគត
    - ០ ផ្តល់ការយល់ដឹង អំពីច្បាប់ និងគោលនយោបាយពាក់ព័ន្ធអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់តាមមុខសញ្ញារបស់ស្ថាប័នរៀងៗខ្លួន
    - ០ បង្កើតសម្ភារៈអប់រំផ្សព្វផ្សាយ រៀបចំយុទ្ធនាការតាមគ្រប់រូបភាព ក្នុងកម្មវិធីសិក្សា វេទិកាសាធារណៈតាមសហគមន៍ និងតាមបណ្តាញផ្សព្វផ្សាយនានា
    - ០ ផ្តល់ការយល់ដឹងដល់គ្រូតាមបណ្តាគ្រឹះស្ថានសិក្សា និងសាលាបណ្តុះបណ្តាលគ្រូគ្រប់កម្រិតឲ្យយល់ដឹងអំពីអំពើជួញដូរមនុស្ស ផលប៉ះពាល់ កលល្បិចរបស់ជនល្មើសជួញដូរមនុស្ស និងការធ្វើអាជីវកម្មពលកម្ម និងផ្លូវភេទ ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្សដើម្បីអប់រំបន្តដល់យុវសិស្ស និងយុវវ័យក្នុងសហគមន៍
    - ០ ផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ក្នុងការអប់រំតម្រង់ទិស កុមារ យុវជនក្នុងសាលា និងក្នុងសហគមន៍ សំដៅលើកកម្ពស់កម្រិតនៃការទទួលបានការសិក្សាអប់រំ បំណិនជីវិត ជំនាញបច្ចេកទេស ពង្រីកកម្មវិធីតម្រង់ទិសវិជ្ជាជីវៈ និងមុខរបរ សំដៅលើកកម្ពស់ជីវភាពរស់នៅ កាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន
- សហការជាមួយវិស័យឯកជននិងទីភ្នាក់ងារជ្រើសរើសពលករ ឲ្យយកចិត្តទុកដាក់អំពីកម្រិតវប្បធម៌ និងបង្កលក្ខណៈឲ្យបុគ្គលិក កម្មកររោងចក្រ សហគ្រាស និងពលករទេសន្តរប្រវេសន៍ មានឱកាសអភិវឌ្ឍន៍ចំណេះដឹង និងសមត្ថភាពជំនាញ
- ទទួលអនុវត្តគោលនយោបាយ គោលការណ៍ណែនាំផ្សេងៗរបស់រាជរដ្ឋាភិបាល និងតាមការណែនាំរបស់គ.ជ.ប.ជ
- ពិនិត្យ កែលំអសារ និងរូបភាពផ្សព្វផ្សាយជាសាធារណៈផ្សេងៗដើម្បីឲ្យទទួលបានលទ្ធផលជាវិជ្ជមាន ដែលអាចកាត់បន្ថយ និងលុបបំបាត់បទល្មើសជួញដូរមនុស្សគ្រប់រូបភាព
- រៀបចំកិច្ចប្រជុំប្រចាំខែ និងកិច្ចប្រជុំដទៃទៀតតាមការចាំបាច់
- ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលសកម្មភាពនៃការអនុវត្តការងារ ទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ និងរបាយការណ៍ ត្រីមាស ឆមាស ឆ្នាំ ដើម្បីបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ
- ប្រជុំក្រុមការងារទៀងទាត់ប្រចាំខែ និងកិច្ចប្រជុំផ្សេងទៀត តាមការចាំបាច់
- ចូលរួមសកម្មភាពដទៃទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ ។

ប្រការ៤.-

ក្រុមការងារការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមានសមាសភាពមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ដែលបាន និងកំពុងធ្វើសកម្មភាពក្នុងគោលដៅជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

ក. សមាសភាព៖

- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ក.ស.អ.យ) ប្រធាន
- រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ក.ស.អ.យ អនុប្រធានអចិន្ត្រៃយ៍
- តំណាងក្រសួងកិច្ចការនារី អនុប្រធាន
- តំណាងអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អនុប្រធាន
- តំណាងក្រសួងយុត្តិធម៌ អនុប្រធាន
- តំណាងក្រសួងការបរទេស អនុប្រធាន
- តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សមាជិក
- អគ្គនាយកបច្ចេកទេស ឬអគ្គនាយករង ក.ស.អ.យ សមាជិក
- តំណាងក្រសួងព័ត៌មាន សមាជិក
- តំណាងក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- តំណាងក្រសួងសុខាភិបាល សមាជិក
- តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ សមាជិក
- តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ សមាជិក
- តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក
- តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- តំណាងទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ សមាជិក
- តំណាងកាកបាទក្រហមកម្ពុជា សមាជិក
- តំណាងសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ សមាជិក
- តំណាងសហភាពសហព័ន្ធយុវជន សមាជិក
- តំណាងអង្គការដៃគូជាតិ និងអន្តរជាតិដទៃទៀត សមាជិក

ខ. ភារកិច្ច៖

ក្រុមការងារការពារជនរងគ្រោះ មានភារកិច្ចដូចតទៅ ៖

- ពង្រឹង និងពង្រីកកិច្ចសហការរវាងសមាជិកក្នុងក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្ថានរដ្ឋ ឯកជន និងអង្គការដៃគូ ទាំងនៅក្នុងស្រុក ទាំងនៅប្រទេសពាក់ព័ន្ធដើម្បី៖
    - ០ រៀបចំបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងថវិកាសម្រាប់ការងារការពារជនរងគ្រោះ និងដាក់ជូន គ.ជ.ប.ជ ពិនិត្យ និងផ្តល់យោបល់
    - ០ ផ្តល់ព័ត៌មាន កំណត់អត្តសញ្ញាណជនរងគ្រោះឱ្យបានត្រឹមត្រូវនិងជួយជនរងគ្រោះឱ្យបានទាន់ពេលវេលា

- ជួយឲ្យជនរងគ្រោះមានសិទ្ធិទទួលបាននូវសេវាសមស្រប និងមានគុណភាពឆ្លើយតបទៅនឹងកម្រិតនៃភាពរងគ្រោះ មានជាអាទិ៍សេវាថែទាំ ការការពារផ្លូវច្បាប់ ការផ្តល់ប្រឹក្សា សេវាសុខភាព សេវាសង្គមកិច្ច ការស្តារនីតិសម្បទា ការធ្វើមាតុភូមិនិវត្តន៍ ការធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ឬសហគមន៍
- លើកកម្ពស់សិទ្ធិជនរងគ្រោះក្នុងការចូលរួមក្នុងសកម្មភាពនានាដោយគ្មានការរើសអើង
- លើកកម្ពស់ជីវភាពរស់នៅ ដល់ជនរងគ្រោះតាមរយៈការផ្តល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បច្ចេកទេសកែច្នៃក្នុងមុខរបរ ឥណទាន អប់រំសីលធម៌និងបំណិនជីវិត ជាដើម
- ផ្តល់កិច្ចការពារផ្លូវច្បាប់ដោយជួយរកនិង/ឬផ្តល់សេវាផ្នែកច្បាប់ដល់ជនរងគ្រោះឆ្លើយតបទៅនឹងលក្ខ័ណ្ឌ និងកម្រិតនៃភាពរងគ្រោះរបស់ជន ឬក្រុមគោលដៅ
- ទទួលយកជនរងគ្រោះដោយអំពើជួញដូរ ឬកេងប្រវ័ញ្ច ដែលធ្វើមាតុភូមិនិវត្តន៍ ដើម្បីទទួលបានការស្តារនីតិសម្បទា សេវានានា និងធ្វើសមាហរណកម្ម
- តាមដាន និងគ្រប់គ្រងករណីជាប្រព័ន្ធ និងចងក្រងប្រព័ន្ធទិន្នន័យ

- ចូលរួមតាមដាន ត្រួតពិនិត្យការអនុវត្តសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធ ចងក្រងឯកសារ មេរៀនបទពិសោធន៍ ករណីសិក្សា ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការអនុវត្តសកម្មភាពការពារជនរងគ្រោះ
- លើកកម្ពស់គុណភាពសេវាកម្មតាមមណ្ឌលថែទាំជនរងគ្រោះឲ្យស្របតាមបទដ្ឋានអប្បរមានៃការថែទាំជំនួស
- សហការជាមួយក្រសួងយុត្តិធម៌ ដើម្បីសិក្សាអំពីនីតិវិធីនៃការផ្តល់នីតិសម្បទាដល់មណ្ឌលថែទាំជនរងគ្រោះ និងបង្កើតជាមណ្ឌលគំរូដែលមានលក្ខណៈងាយស្រួល និងផ្តល់សេវាជាកញ្ចប់
- ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលសកម្មភាពនៃការអនុវត្តការងារ ទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ និងរបាយការណ៍ ត្រីមាស ឆមាស ឆ្នាំ ដើម្បីបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ
- ប្រជុំក្រុមការងារទៀងទាត់ប្រចាំខែ និងកិច្ចប្រជុំផ្សេងទៀត តាមការចាំបាច់
- ចូលរួមសកម្មភាពដទៃទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ ។

**ប្រការ ៥.-**

ក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ និងមានសមត្ថកិច្ចជំនាញមកពីក្រសួង ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ដែលបាននិងកំពុងធ្វើសកម្មភាពដោយស្របច្បាប់ និងមានការទទួលស្គាល់ពីរាជរដ្ឋាភិបាល ក្នុងគោលដៅរួមចំណែកធ្វើឲ្យសកម្មភាពបង្ក្រាបបទល្មើស និងសង្គ្រោះជនរងគ្រោះដោយអំពើជួញដូរមនុស្ស អាជីវកម្មពលកម្ម និងអាជីវកម្មផ្លូវភេទ ប្រកបដោយប្រសិទ្ធភាព ។

ក. សមាសភាព៖

| | |
|---|---|
| - អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | ប្រធាន |
| - អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធានអចិន្ត្រៃយ៍ |
| - តំណាងអគ្គមហាអយ្យការអមតុលាការកំពូល | អនុប្រធាន |
| - ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សក្រសួងមហាផ្ទៃ | អនុប្រធាន |
| - តំណាងក្រសួងយុត្តិធម៌ | អនុប្រធាន ៥ |

- តំណាងអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ អនុប្រធាន
- តំណាងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- តំណាងក្រសួងកិច្ចការនារី សមាជិក
- តំណាងក្រសួងការបរទេស សមាជិក
- តំណាងក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- តំណាងក្រសួងសុខាភិបាល សមាជិក
- តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ សមាជិក
- តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក
- តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- តំណាងទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ សមាជិក
- តំណាងអង្គការដៃគូជាតិ និងអន្តរជាតិដទៃទៀត សមាជិក

ខ. ភារកិច្ចៈ

ក្រុមការងារអនុវត្តច្បាប់ មានភារកិច្ចដូចតទៅ ៖

ពង្រឹងកិច្ចសហការរវាងសមាជិកក្នុងក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងដៃគូពាក់ព័ន្ធដទៃទៀត ដើម្បីៈ

- តាមដានត្រួតពិនិត្យសភាពការណ៍ និងការវិវត្តន៍ប្រែប្រួលនៃបទល្មើស គលល្បិចជនល្មើស ទំនោរ និងបញ្ហាសង្គមដែលជាកត្តាអូសទាញ ឬជំរុញ ឬនាំប្រជាពលរដ្ឋទៅរកភាពរងគ្រោះដោយការជួញដូរមនុស្ស ការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់រូបភាព
- រៀបចំបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ វិធានការ ផែនការ និងថវិកា សម្រាប់ការងារបង្ក្រាបបទល្មើសជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះ ជាក់ជូន គ.ជ.ប.ជ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជន អង្គការដៃគូ ស្ថានទូត និងសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងជាអន្តរជាតិ ដើម្បីប្រមូលពត៌មាន ដែលអាចធានាដល់វិធានការបង្ក្រាបបទល្មើស ចាប់ជនល្មើសនិងជួយជនរងគ្រោះ ក្នុងករណីអំពើជួញដូរមនុស្សឆ្លងដែនទាន់ពេលវេលា
- លើកកម្ពស់ការអនុវត្តអនុសញ្ញាណ សន្ធិសញ្ញា និងកត្តិកាសញ្ញាអន្តរជាតិ ច្បាប់ និងគោលនយោបាយជាតិ គោលការណ៍ណែនាំ កិច្ចព្រមព្រៀង អនុស្សរណៈទ្វេភាគី ពហុភាគី ផែនការនិងបទដ្ឋានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជាមួយបណ្តាភាគីពាក់ព័ន្ធក្នុងប្រទេស ក្រៅប្រទេស ក្នុងតំបន់ និងជាអន្តរជាតិ ឱ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធិផលខ្ពស់
- ចូលរួមតាមដាន ត្រួតពិនិត្យការងារជំនាញមន្ត្រីអនុវត្តច្បាប់ នៅតាមបណ្តាមូលដ្ឋានថ្នាក់ក្រោមជាតិ ទីតាំងឈរជើងរបស់កម្លាំងសមត្ថកិច្ចរបស់រាជធានី ខេត្តជាប់ព្រំដែន និងមានវិធានការតឹងរឹងសំដៅលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់
- ជំរុញការអនុវត្តសកម្មភាពរបស់មន្ត្រីអនុវត្តច្បាប់នៅថ្នាក់ក្រោមជាតិ
- លើកកម្ពស់ការប្រើប្រាស់សេវាទូរស័ព្ទទាន់ហេតុការណ៍ និងបានចាត់វិធានការសមស្របទាន់ពេលវេលា

- ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលសកម្មភាពនៃការអនុវត្តច្បាប់ទៅអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ និងរបាយការណ៍ ត្រីមាស ឆមាស ឆ្នាំ ដើម្បីបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ
- ប្រជុំក្រុមការងារទៀងទាត់ប្រចាំខែ និងកិច្ចប្រជុំផ្សេងទៀត តាមការចាំបាច់
- ចូលរួមសកម្មភាពដទៃទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ ។

**ប្រការ ៦.-**

ក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ និងមានសមាសភាពមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធជាតិនិងអន្តរជាតិ ដែលបាន និងកំពុងធ្វើសកម្មភាពក្នុងគោលដៅផ្តល់កិច្ចការពារផ្នែកច្បាប់ ដើម្បីផ្តល់ភាពយុត្តិធម៌ជូនជនរងគ្រោះ និងផ្តន្ទាទោសជនល្មើសនៃអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ជាពិសេសលើស្ត្រីនិងកុមារ ។

ក. សមាសភាព៖

- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ — ប្រធាន
- រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ — អនុប្រធានអចិន្ត្រៃយ៍
- តំណាងអគ្គមហាអយ្យការអមសាលាឧទ្ធរណ៍ — អនុប្រធាន
- តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ — អនុប្រធាន
- តំណាងអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ — អនុប្រធាន
- តំណាងអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងយុត្តិធម៌ — សមាជិក
- តំណាងក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ — សមាជិក
- តំណាងក្រសួងការបរទេស — សមាជិក
- តំណាងក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា — សមាជិក
- តំណាងរាជអាវុធហត្ថលើផ្ទៃប្រទេស — សមាជិក
- តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ — សមាជិក
- តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ — សមាជិក
- តំណាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ក្រសួងមហាផ្ទៃ — សមាជិក
- តំណាងអង្គការដៃគូជាតិ និងអន្តរជាតិ — សមាជិក

ខ. ភារកិច្ច៖

ក្រុមការងារកិច្ចការយុត្តិធម៌ មានភារកិច្ច ៖

- រៀបចំនីតិវិធី និងផែនការសម្រាប់ការប្រមូលទិន្នន័យនៃការផ្តន្ទាទោស ករណីជួញដូរមនុស្សឲ្យបានជាប្រចាំ
- ប្រមូលទិន្នន័យពាក់ព័ន្ធនឹងដំណើរការផ្តន្ទាទោសករណីជួញដូរមនុស្ស ពីរបស់ស្ថាប័នអយ្យការ និងសាលាដំបូងរាជធានី ខេត្តឱ្យបានទៀងទាត់តាមពេលវេលាកំណត់
- ពង្រឹងកិច្ចសហការរវាងស្ថាប័នអយ្យការ និងមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីការងារប្រមូលពត៌មាន និង ភស្តុតាងឲ្យបានគ្រប់គ្រាន់ដើម្បីបម្រើឲ្យការងារផ្តន្ទាទោស ៥

- ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ គោលការណ៍ណែនាំ វិធានការ និងផែនការនានា ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សឱ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់
- ផ្សព្វផ្សាយអប់រំ និងបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ជំរុញកិច្ចសហប្រតិបត្តិការជាមួយអន្តរជាតិ ក្នុងការអនុវត្តច្បាប់ដើម្បីបង្ក្រាបអំពើជួញដូរមនុស្ស ជាអាទិ៍ ការអនុវត្តសិទ្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ និងការធ្វើបត្យាប័ន នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ល។
- តាមដាន ត្រួតពិនិត្យការអនុត្តនីតិវិធីពាក់ព័ន្ធការផ្តន្ទាទោសនិងផ្លាស់ប្តូរបទពិសោធន៍ជាក់ស្តែងរវាងគ្នា ដើម្បីលើកកម្ពស់គុណភាពប្រព័ន្ធយុត្តិធម៌
- រៀបចំផែនការសកម្មភាព និងបង្កើតយុទ្ធសាស្ត្រឆ្លើយតបទៅនឹងសកម្មភាពការងារចំពោះមុខ
- ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលសកម្មភាពនៃការអនុវត្តការងារ ទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ និងរបាយការណ៍ ត្រីមាស ឆមាស ឆ្នាំ ដើម្បីបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ
- ប្រជុំក្រុមការងារទៀងទាត់ប្រចាំខែ និងកិច្ចប្រជុំផ្សេងទៀត តាមការចាំបាច់
- ចូលរួមសកម្មភាពដទៃទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ ។

**ប្រការ ៧.-**

ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយក្រសួងកិច្ចការនារី និងមានសមាសភាពមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ដែលបាន និងកំពុងធ្វើសកម្មភាពដោយមានកិច្ចសហការជាមួយប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងអន្តរជាតិ ក្នុងគោលដៅពង្រឹងកិច្ចសហការក្នុងការរៀបចំ និងជំរុញការអនុត្តន៍ កិច្ចព្រមព្រៀង អនុស្សរណៈទ្វេភាគី ពហុភាគី ក្នុងគោលដៅជួយការពារប្រជាពលរដ្ឋកម្ពុជាពីភាពរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចគ្រប់រូបភាពជាពិសេស លើស្ត្រី និងកុមារ នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ក. សមាសភាពៈ

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| - ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកកិច្ចការខេត្រព្រំដែនកម្ពុជឆ្លងដែនក្នុងតំបន់អាស៊ាន | អនុប្រធាន |
| - តំណាងក្រសួងយុត្តិធម៌ | អនុប្រធាន |
| - តំណាងក្រសួងការបរទេស | អនុប្រធាន |
| - តំណាងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | អនុប្រធាន |
| - អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី | សមាជិក |
| - អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម | សមាជិក |
| - តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | សមាជិក |
| - តំណាងក្រសួងព័ត៌មាន | សមាជិក |
| - តំណាងក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - តំណាងក្រសួងសុខាភិបាល | សមាជិក |

- តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ សមាជិក
- តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ សមាជិក
- តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក្រសួងមហាផ្ទៃ សមាជិក
- តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- តំណាងទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ សមាជិក
- តំណាងអង្គការដៃគូជាតិ និងអន្តរជាតិដទៃទៀត សមាជិក

ខ. ភារកិច្ចៈ

ពង្រឹងកិច្ចសហការរវាងសមាជិកក្នុងក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងដៃគូពាក់ព័ន្ធដទៃទៀត ដើម្បីៈ

- រៀបចំយុទ្ធសាស្ត្រ ផែនការ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីឆ្លើយតបទៅនឹងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស
- ផ្សព្វផ្សាយលទ្ធផលនៃកិច្ចសហការ ព្រមទាំងសភាពការណ៍ និងការវិវត្តន៍ប្រែប្រួលនៃអំពើជួញដូរមនុស្ស ការរំលោភបំពាន និងការកេងប្រវ័ញ្ចក្នុងមហាអនុតំបន់មេគង្គ ក្នុងប្រទេសសមាជិកសហគមន៍អាស៊ីអាគ្នេយ៍ និងប្រទេសក្រៅតំបន់ ជាអន្តរជាតិដើម្បីរិះរកវិធានការកាត់បន្ថយឬលុបបំបាត់បទល្មើសជួញដូរមនុស្សឆ្លងដែន
- សម្របសម្រួលជាមួយគ.ជ.ប.ជ និងក្រុមការងារជំនាញអន្តរក្រសួង ដើម្បីតាមដានវាយតម្លៃ និងជម្រុញការអនុវត្តផែនការសហប្រតិបត្តិការ ទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសពាក់ព័ន្ធ
- សហការជាមួយក្រុមការងារពាក់ព័ន្ធដើម្បីលើកកម្ពស់ការអនុវត្តអនុសញ្ញា សន្ធិសញ្ញា និងកត្តិកាសញ្ញា កិច្ចព្រមព្រៀង អនុស្សរណៈទ្វេភាគី ពហុភាគី ផែនការនិងបទដ្ឋានពាក់ព័ន្ធនឹងកិច្ចសហការរវាងជាមួយបណ្តាប្រទេសភាគីពាក់ព័ន្ធក្នុងប្រទេស ក្រៅប្រទេស ក្នុងតំបន់ និងជាអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឱ្យទទួលបានប្រសិទ្ធភាព និងប្រសិទ្ធិផលខ្ពស់
- ចូលរួម តាមដាន ត្រួតពិនិត្យការអនុវត្តសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធទៅតាមផែនការ និងយុទ្ធសាស្ត្រដែលបានឯកភាព
- រៀបចំ និងសម្របសម្រួលការចូលរួមកិច្ចប្រជុំ សិក្ខាសាលា សន្និសីទជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងការជួញដូរមនុស្ស
- ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលសកម្មភាពនៃកិច្ចសហការ និងទិសដៅបន្តទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ និងរបាយការណ៍ ត្រីមាស ឆមាស ឆ្នាំ ដើម្បីបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ
- ប្រជុំក្រុមការងារទៀងទាត់ប្រចាំខែ និងកិច្ចប្រជុំផ្សេងទៀត តាមការចាំបាច់
- ចូលរួមសកម្មភាពដទៃទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ ។

**ប្រការ ៨.-**

ក្រុមការងារទេសន្តរប្រវេសន៍ ដឹកនាំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានសមាសភាពមកពីក្រសួង និងស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ដែលបាន និងកំពុងធ្វើសកម្មភាពក្នុងគោលដៅតាម

ដាន និងទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មពលកម្ម និងអាជីវកម្មផ្លូវភេទ ក្រោមរូបភាពទេសន្តរប្រវេសន៍ ទាំងតាមប្រព័ន្ធស្របច្បាប់ និងតាមប្រព័ន្ធមិនស្របច្បាប់ ។

ក. សមាសភាព៖

- រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធាន
- រដ្ឋលេខា ឬអនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធានអចិន្ត្រៃយ៍
- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន
- តំណាងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អនុប្រធាន
- តំណាងក្រសួងយុត្តិធម៌ អនុប្រធាន
- អគ្គនាយក អគ្គនាយកដ្ឋានហត្ថពលកម្ម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- តំណាងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ សមាជិក
- តំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ក្រសួងមហាផ្ទៃ សមាជិក
- តំណាងអគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ សមាជិក
- តំណាងនាយកដ្ឋានកណ្តាលនគរបាលព្រំដែន ក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិក
- តំណាងក្រសួងព័ត៌មាន សមាជិក
- តំណាងក្រសួងសុខាភិបាល សមាជិក
- តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- តំណាងទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន ក្រសួងការពារជាតិ សមាជិក
- តំណាងសមាគមទីភ្នាក់ងារជ្រើសរើសពលករ សមាជិក
- តំណាងកាកបាទក្រហមកម្ពុជា សមាជិក
- តំណាងសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ សមាជិក
- តំណាងសហភាពសហព័ន្ធយុវជន សមាជិក
- តំណាងអង្គការដៃគូជាតិ និងអន្តរជាតិដទៃទៀត សមាជិក

ខ. ភារកិច្ច៖

ក្រុមការងារគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ មានភារកិច្ច ៖

- ពង្រឹងកិច្ចសហការរវាងក្រសួង ស្ថាប័នជាសមាជិក អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងក្រុមការងារពាក់ព័ន្ធ ដើម្បី
  - រៀបចំយុទ្ធសាស្ត្រដើម្បីឆ្លើយតបទៅនឹងការគ្រប់គ្រងទេសន្តរប្រវេសន៍
  - ដាក់ចេញនូវវិធានការសមស្រប ដែលឆ្លើយតបទៅនឹងការលើកកម្ពស់សុវត្ថិភាពទេសន្តរប្រវេសន៍គ្រប់រូបភាពព្រមទាំងជួយដល់ជនរងគ្រោះទាំងនៅក្នុងប្រទេសនិងទាំងនៅក្នុងប្រទេសគោលដៅ
  - ជម្រុញអនុវត្ត តាមដាន និងវាយតម្លៃការអនុវត្តន៍គោលនយោបាយ សេចក្តីសម្រេច គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ផែនការ បទដ្ឋាននានាពាក់ព័ន្ធនឹងការគ្រប់គ្រងទេសន្តរ

ប្រវេសន៍ និងលើកកម្ពស់សុវត្ថិភាពពលករខ្មែរដែលទៅធ្វើការនៅក្រៅប្រទេស តាំងពីពេលចាកចេញពីផ្ទះ រហូតត្រឡប់មកដល់ផ្ទះវិញ

- ជំរុញឱ្យមានកិច្ចព្រមព្រៀង ឬអនុស្សរណៈទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសពាក់ព័ន្ធ ក្នុងតំបន់ និងអន្តរជាតិពាក់ដើម្បីការពារសិទ្ធិស្របច្បាប់របស់ពលករពលការិនីទេសន្តរប្រវេសន៍
- សហការជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀបចំផែនការ និងតាមដាន ត្រួតពិនិត្យ វាយតម្លៃការអនុវត្តរបស់ក្រុមហ៊ុនជ្រើសរើសពលករស្របច្បាប់ដើម្បីមានវិធានការ ឬលើកសរសើរ
- ចាត់វិធានការលុបបំបាត់មេខ្យល់ជួញដូរមនុស្ស និងដោះស្រាយភាពរងគ្រោះរបស់ពលករ
- រៀបចំផែនការសកម្មភាព និងបង្កើតយុទ្ធសាស្ត្រឆ្លើយតបទៅនឹងសកម្មភាពការងារចំពោះមុខ
- ធ្វើរបាយការណ៍ទៀងទាត់អំពីលទ្ធផលសកម្មភាពនៃការអនុវត្តការងារ ទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ និងរបាយការណ៍ ត្រីមាស ឆមាស ឆ្នាំ ដើម្បីបូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ
- ប្រជុំក្រុមការងារទៀងទាត់ប្រចាំខែ និងកិច្ចប្រជុំផ្សេងទៀត តាមការចាំបាច់
- ចូលរួមសកម្មភាពដទៃទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ ។

**ប្រការ ៩.-**

សមាសភាពជាក់ស្តែងរបស់ក្រុមការងារនីមួយៗ ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់គ.ជ.ប.ជ។

ក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ននីមួយៗ ត្រូវលើកគម្រោងថវិការួមសម្រាប់សកម្មភាពរួមរបស់ក្រុមការងារដែលត្រូវដាក់បញ្ចូលក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នជាប្រធានក្រុមការងារ ។ រីឯថវិកាដែលត្រូវអនុវត្តសកម្មភាពជាជំនាញដោយឡែករបស់ក្រសួងស្ថាប័ន គឺជាបន្ទុករបស់សាមីក្រសួងស្ថាប័នរៀងៗខ្លួន ។

ក្រុមការងារ មានសិទ្ធិទទួលយកថវិកា និងការគាំទ្រពីដៃគូជាតិ និងអន្តរជាតិ ផ្នែកឯកជន និងពីប្រភពផ្សេងទៀត ដើម្បីបំរើឱ្យសកម្មភាពរួមរបស់ក្រុមការងារ ក្នុងគោលដៅប្រឆាំងអំពើជួញដូរមនុស្សទៅតាមមុខសញ្ញារៀងៗខ្លួន ដោយត្រូវរាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ ដើម្បីបូកសរុប ។

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ១១.-**

សេចក្តីសំរេចនេះមានអនុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែ តុលា ឆ្នាំ២០១៤

**ប្រធាន គ.ជ.ប.ជ**

**ស ខេង**

**កន្លែងទទួល៖**

- ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យក្រសួងមហាផ្ទៃ
- សមាជិកគណៈកម្មាធិការ គ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ : ០០១/គស.ស.ជ.
១៥

# សេចក្តីសម្រេច
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ថ្នាក់ក្រោមជាតិ

## គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល (នីតិកាលទី៥) នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើត គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)
- បានឃើញអនុក្រឹត្យលេខ២៧៣អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

# សម្រេច

**ប្រការ១.-**

សេចក្តីសម្រេចនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅថ្នាក់ក្រោមជាតិ ដែលជាយន្តការអន្តរមន្ទីរ ស្ថាប័ន សម្រាប់សម្របសម្រួលដឹកនាំការអនុវត្តយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស និងការពារជនរងគ្រោះនៅក្នុងដែនសមត្ថកិច្ចនៃរាជធានី ខេត្ត នីមួយៗ។

**ប្រការ២.-**

ត្រូវបានបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងដែនសមត្ថកិច្ចរាជធានី ហៅកាត់ថា គ.រ.ប.ជ និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅក្នុងដែនសមត្ថកិច្ចខេត្តនីមួយៗនៃព្រះរាជាណាចក្រកម្ពុជា ដែលហៅកាត់ថា គ.ខ.ប.ជ ។

គ.រ.ប.ជ ដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី និងគ.ខ.ប.ជ ដឹកនាំដោយអភិបាលនៃគណៈអភិបាលខេត្ត ដែលមានសមាជិកជាប្រធានមន្ទីរពាក់ព័ន្ធជុំវិញរាជធានី ខេត្ត ព្រះរាជអាជ្ញាអមសាលាដំបូង

រាជធានី ខេត្ត ស្នងការនគរបាលរាជធានី ខេត្ត មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត មេបញ្ជាការកម្លាំងឈរជើងតាមព្រំដែន ច្រកអន្តរជាតិ ច្រកតំបន់ ច្រកទ្វេភាគី (បើមាន) អភិបាលខណ្ឌ ស្រុក ក្រុង និងប្រធានអង្គភាពពាក់ព័ន្ធសំខាន់ៗផ្សេងទៀតក្នុងរាជធានី ខេត្ត (បើមាន) ។

សមាសភាពនៃ គ.រ.ប.ជ ឬ គ.ខ.ប.ជ ត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស តាមការស្នើសុំរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ។

**ប្រការ៣.-**

គ.រ.ប.ជ ឬ គ.ខ.ប.ជ មានលេខាធិការដ្ឋានមួយជាអង្គភាពជំនួយដើម្បីដឹកនាំការងារប្រចាំថ្ងៃ ដែលមានការិយាល័យការងារអចិន្ត្រៃយ៍នៅក្នុងសាលារាជធានី ខេត្ត ។

លេខាធិការដ្ឋាន ដឹកនាំដោយអភិបាលរងរាជធានី ឬខេត្ត ០១រូប អមដោយអនុប្រធានលេខាធិការដ្ឋាន ០១រូប មានឋានៈជានាយករងរដ្ឋបាល រាជធានី ឬខេត្ត និងមានមន្ត្រីមួយចំនួនជាជំនួយតាមការចាំបាច់ មកពីក្របខណ្ឌសាលារាជធានី ខេត្ត ឬពីស្នងការដ្ឋាន នគរបាលរាជធានី ខេត្ត ឬពីមន្ទីរស្ថាប័ន ពាក់ព័ន្ធ ។

សមាសភាពនៃលេខាធិការដ្ឋាន ត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការរាជធានី (គ.រ.ប.ជ) ឬគណៈកម្មាធិការខេត្ត (គ.ខ.ប.ជ )។

**ប្រការ៤.-**

អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌ ត្រូវចាត់តាំងមន្ត្រីយ៉ាងតិច ០១រូប ឱ្យទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសម្រាប់ ក្រុង ស្រុក ខណ្ឌ ដែលហៅកាត់ថា ម.ក្រ.ប.ជ (សម្រាប់ក្រុង) ម.ស្រ.ប.ជ (សម្រាប់ស្រុក) និង ម.ខ.ប.ជ (សម្រាប់ខណ្ឌ) ។

**ប្រការ៥.-**

មេឃុំ ចៅសង្កាត់ ត្រូវចាត់តាំងសមាជិកក្រុមប្រឹក្សាឃុំសង្កាត់មួយរូបឱ្យទទួលបន្ទុកការងារប្រឆាំងការជួញដូរមនុស្ស ដែលហៅកាត់ថា ម.ស.ប.ជ (សម្រាប់សង្កាត់) និងម.ឃ.ប.ជ (សម្រាប់ឃុំ) និងមានមេភូមិជាជំនួយទៅតាមការងារជាក់ស្តែងរបស់ឃុំសង្កាត់ ។

**ប្រការ៦.-**

គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី (គ.រ.ប.ជ) ឬគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្ត (គ.ខ.ប.ជ) នីមួយៗ មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ក្រោមការដឹកនាំរបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ជំរុញអនុវត្តច្បាប់ គោលនយោបាយ ផែនការជាតិ ផែនការខេត្ត និងយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងដែនសមត្ថកិច្ចរបស់រាជធានី និងខេត្តនីមួយៗ ។
- ជាបញ្ជាការផ្ទាល់លើលេខាធិការដ្ឋាន គ.រ.ប.ជ ឬ គ.ខ.ប.ជ តាមដានត្រួតពិនិត្យ វាយតម្លៃបទល្មើស និងភាពរីកចម្រើននៃការអនុវត្តការងារ
- ពិនិត្យ និងសម្រេចលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដែលស្នើឡើងដោយលេខាធិការដ្ឋានសម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់រាជធានី ខេត្ត ដើម្បីដាក់បញ្ចូលក្នុងកញ្ចប់ថវិការាជធានី ខេត្ត
- បង្កើតក្រុមការងារអន្តរមន្ទីរ ស្ថាប័ន មួយចំនួនដើម្បីធ្វើជាយន្តការសម្រាប់ការអនុវត្តជំនាញ
- ដឹកនាំមន្ទីរ ស្ថាប័ន ក្រុង ស្រុក អង្គការដៃគូជាតិ អន្តរជាតិពាក់ព័ន្ធ និងទំនាក់ទំនងសហការជាមួយបណ្តាខេត្តនៃប្រទេសជាប់ព្រំដែន ដើម្បីបង្ការទប់ស្កាត់បទល្មើស និងជួយជនរងគ្រោះទាន់ពេលវេលា

តាមគោលការណ៍កំណត់របស់ថ្នាក់ជាតិ

- ដាក់ចេញវិធានការនានាតាមការចាំបាច់ ដើម្បីជំរុញ និងលើកកម្ពស់ការទទួលខុសត្រូវរបស់មន្ទីរ ស្ថាប័ន អង្គភាពពាក់ព័ន្ធក្រោមឱវាទ ដើម្បីអនុវត្តសកម្មភាព ផែនការ គោលនយោបាយ និងគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល
- សម្របសម្រួល និងជំរុញកម្លាំងសមត្ថកិច្ចឱ្យបង្កើនការស៊ើបអង្កេតបទល្មើស និងស្វែងចាប់ជនល្មើសពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សដើម្បីផ្តន្ទាទោស
- ប្រជុំសមាជិកទៀងទាត់ប្រចាំត្រីមាស ឆមាស ឆ្នាំ របស់គណៈកម្មាធិការរាជធានី ខេត្ត ។ ក្នុងករណីចាំបាច់ ប្រធានអាចកោះអញ្ជើញសមាជិកជួបប្រជុំវិសាមញ្ញបាន ។
- ពិនិត្យសម្រេចលើរបាយការណ៍ មុននឹងបញ្ជូនទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ តាមកាលកំណត់
- អនុវត្តភារកិច្ចផ្សេងទៀត តាមការណែនាំចង្អុលទិសពីគណៈកម្មាធិការជាតិ ។

**ប្រការ៧.-**

លេខាធិការដ្ឋាន គ.រ.ប.ជ ឬ គ.ខ.ប.ជ មានភារកិច្ច ៖

- ជាជំនួយការប្រតិបត្តិ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី ខេត្ត ក្នុងការអនុវត្តភារកិច្ចដែលដាក់ចុះដោយគណៈកម្មាធិការជាតិ រាជធានី ខេត្ត លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- រៀបចំកិច្ចប្រជុំរបស់ គ.រ.ប.ជ ឬ គ.ខ.ប.ជ ប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ និងកិច្ចប្រជុំវិសាមញ្ញផ្សេងទៀត តាមការចាំបាច់
- ផ្សព្វផ្សាយទូលំទូលាយអំពីច្បាប់ គោលនយោបាយ បទដ្ឋានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស
- ដឹកនាំ សម្របសម្រួល រៀបចំ ឬចូលរួមកិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ចសិក្សា និងសន្និសីទពាក់ព័ន្ធផ្សេងៗ
- ពង្រឹង និងពង្រីកទំនាក់ទំនងសហការក្នុងក្រុមការងារជំនាញអន្តរមន្ទីរ ស្ថាប័ន និងអង្គការដៃគូ
- លើកផែនការពង្រឹងសមត្ថភាពមន្ត្រីលេខាធិការដ្ឋាន គ.រ.ប.ជ ឬ គ.ខ.ប.ជ និងមន្ត្រីពាក់ព័ន្ធតាមមន្ទីរស្ថាប័នក្រោមឱវាទ និងមន្ត្រីទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រុង ស្រុក ខណ្ឌ ទៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល
- គ្រប់គ្រង និងតាមដានលំហូរពលករទេសន្តប្រវេសន៍ ទប់ស្កាត់ភាពមិនប្រក្រតីនៃចំណាកស្រុក តាមដានកលល្បិចជនខិលខូចទាំងក្នុងប្រព័ន្ធស្របច្បាប់ និងមិនស្របច្បាប់
- តាមដាន និងអប់រំផ្សព្វផ្សាយទូលំទូលាយតាមគ្រប់រូបភាព អំពីល្បិចកលជនល្មើស ដើម្បីបង្ការ ទប់ស្កាត់បទល្មើស
- ជំរុញការស៊ើបអង្កេតតាមដានជនសង្ស័យ ឈានទៅការចាប់ខ្លួនដើម្បីផ្តន្ទាទោស
- គាំទ្រការផ្តល់សេវាជួយជនរងគ្រោះ និងជំរុញការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងភាពរងគ្រោះរបស់ប្រជាពលរដ្ឋដោយអំពើជួញដូរមនុស្ស
- បូកសរុបរបាយការណ៍ដែលប្រមូលបានពីក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាពពាក់ព័ន្ធ ប្រចាំខែ ត្រីមាស និងឆ្នាំ ស្តីពីសកម្មភាព លទ្ធផល ភាពប្រឈម ជុំវិញការប្រឆាំងអំពើជួញដូរមនុស្ស និងទិសដៅ ដាក់ជូនអភិបាល រាជធានី-ខេត្ត ដែលជាប្រធាន គ.រ.ប.ជ ឬ គ.ខ.ប.ជ ដើម្បីពិនិត្យ និងចុះហត្ថលេខា រួចបញ្ជូនទៅអគ្គលេខា ធិការដ្ឋានថ្នាក់ជាតិ មិនហួសពីថ្ងៃចុងក្រោយ នៃខែនីមួយៗ ។

- បំពេញការងារផ្សេងទៀត តាមការប្រគល់ជូនពី គ.ជ.ប.ជ និង គ.រ.ប.ជ ឬ គ.ខ.ប.ជ ។

**ប្រការ៨.-**

ម.ក្រ.ប.ជ ឬម.ស.ប.ជ ឬម.ខ.ប.ជ របស់ក្រុង ស្រុក ខណ្ឌ មានភារកិច្ច ៖

- ទទួល និងបញ្ជូនលិខិត បទដ្ឋានគតិយុត្តិ ឬគោលការណ៍ណែនាំផ្សេងៗពី គ.រ.ប.ជ ឬ គ.ខ.ប.ជ ទៅឃុំ សង្កាត់ និងទទួលរបាយការណ៍ឬព័ត៌មានផ្សេងៗពីឃុំ សង្កាត់ ដើម្បីបញ្ជូនទៅគ.រ.ប.ជ ឬគ.ខ.ប.ជ វិញ
- ទំនាក់ទំនង សម្របសម្រួលកិច្ចសហការរវាងក្រសួង មន្ទីរ ស្ថាប័ន អង្គការ ដែលធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធ្វើរបាយការណ៍បូកសរុបការងារ និងលទ្ធផលប្រចាំខែ អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងដែនសមត្ថកិច្ច ក្រុងស្រុក ខណ្ឌ និងដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌ ឬអភិបាលរងទទួលបន្ទុក ពិនិត្យ និងចុះហត្ថលេខាដើម្បីបញ្ជូនទៅលេខាធិការដ្ឋានរាជធានី ខេត្ត មិនហួសពីថ្ងៃទី២៧នៃខែនីមួយៗ ។

**ប្រការ៩.-**

ម.ឃ.ប.ជ របស់ឃុំ ឬម.ស.ប.ជ របស់សង្កាត់ មានភារកិច្ច ៖

- ទទួលភារកិច្ច និងគោលការណ៍ណែនាំពីគណៈកម្មាធិការ ឬលេខាធិការដ្ឋានរាជធានី ខេត្ត តាមរយៈ ម.ក្រ.ប.ជ.ឬ ម.ស្រ.ប.ជ ឬ ម.ខ.ប.ជ
- សម្របសម្រួលសហការ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងសកម្មភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស របស់មន្ត្រីក្រសួង ស្ថាប័ន អាជ្ញាធរ សមត្ថកិច្ច សាលារៀន អង្គការ និងភ្នាក់ងារឯកជននានា ក្នុងឃុំ សង្កាត់របស់ខ្លួន
- ធ្វើបញ្ជីអង្គការសង្គមស៊ីវិលដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សក្នុងឃុំ សង្កាត់របស់ខ្លួន ដោយផ្តល់កិច្ចសហការល្អ និងជំរុញឲ្យធ្វើរបាយការណ៍សកម្មភាពមក ម.ឃ.ប.ជ ឬម.ស.ប.ជ ជាប្រចាំ
- ជំរុញសមត្ថកិច្ចនគរបាលតាមបណ្តាប៉ុស្តិ៍ និងប្រជាពលរដ្ឋតាមដានករណីសង្ស័យ និងរាយការណ៍ ។
- ធ្វើរបាយការណ៍សកម្មភាព និងលទ្ធផលសរុបប្រចាំខែ ដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ ចុះហត្ថលេខា រួចបញ្ជូនទៅម.ស.ប.ជ ឬម.ស.ប.ជ ដើម្បីបូកសរុបប្រចាំខែ រៀងរាល់ថ្ងៃទី២៥នៃខែនីមួយៗ ។

**ប្រការ១០.-**

គ.រ.ប.ជ ឬ គ.ខ.ប.ជ អាចអនុញ្ញាតឱ្យអង្គការ ស្ថាប័ន ក្នុងស្រុក និងអន្តរជាតិដែលបានចុះបញ្ជីជាផ្លូវការជាមួយរាជរដ្ឋាភិបាល សាកលវិទ្យាល័យ ឬផ្នែកឯកជន ដែលកំពុងធ្វើសកម្មភាពក្នុងទិសដៅរួមចំណែកបង្ការ ទប់ស្កាត់ ឬលុបបំបាត់ការជួញដូរមនុស្ស និងជួយជនរងគ្រោះនៅក្នុងដែនសមត្ថកិច្ចរបស់ រាជធានី ខេត្ត ធ្វើជាដៃគូ ដើម្បីពង្រឹង និងពង្រីកកិច្ចសហការ ឬការគាំទ្រដល់ការអនុវត្តច្បាប់ គោលនយោបាយជាតិ យុទ្ធសាស្ត្រ ផែនការជាតិរបស់ គ.ជ.ប.ជ ព្រមទាំងផែនការរបស់ គ.រ.ប.ជ ឬ គ.ខ.ប.ជ ។

**ប្រការ១១.-**

អង្គការ ឬស្ថាប័នដៃគូជាតិ និងអន្តរជាតិ អាចចូលរួមប្រជុំពិគ្រោះពិភាក្សា ផ្លាស់ប្តូរយោបល់ ផ្តល់ប្រឹក្សា ពង្រឹងកិច្ចសហការជាមួយ គ.រ.ប.ជ និង គ.ខ.ប.ជ ដើម្បីគាំទ្របច្ចេកទេស ធនធាន ថវិកា សម្ភារមធ្យោបាយ សំដៅធ្វើឱ្យសម្រេចគោលដៅតាមការអញ្ជើញរបស់ គ.ខ.ប.ជ ជាទៀងទាត់ប្រចាំត្រីមាស ។ រាល់កិច្ចប្រជុំត្រូវមានរបាយការណ៍សកម្មភាព និងលទ្ធផលរបស់អង្គការនីមួយៗ ។

**ប្រការ១២.-**

គ.រ.ប.ជ ឬ គ.ខ.ប.ជ ត្រូវរៀបចំក្រុមការងារជំនាញអន្តរមន្ទីរ ស្ថាប័ន ដែលបើកទូលាយឲ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ ទាំងក្នុងរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាល ជាតិ និងអន្តរជាតិ ផ្នែកឯកជន ។ល។ ដែលមានក្រុមមួយចំនួន ដូចខាងក្រោម ៖

១. ក្រុមការងារបង្ការ ទប់ស្កាត់ ដឹកនាំដោយមន្ទីរអប់រំ យុវជន និងកីឡា

២. ក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៣. ក្រុមការងារអនុវត្តន៍ច្បាប់ ដឹកនាំដោយស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត

៤. ក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

៥. ក្រុមការងារពង្រឹងកិច្ចសហប្រតិបត្តិការ ដឹកនាំដោយមន្ទីរកិច្ចការនារី (ចំពោះខេត្តជាប់ព្រំដែន)

៦. ក្រុមការងារកិច្ចការទេសន្តរប្រវេសន៍ ដឹកនាំដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

សមាសភាព និងតួនាទីភារកិច្ចរបស់ក្រុមការងារនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការរាជធានី ខេត្ត ។

សមាជិកទទួលបន្ទុកការងារបច្ចេកទេសនីមួយៗ ត្រូវសហការអនុវត្តការងាររួមគ្នាតាមជំនាញ សំដៅលើកកម្ពស់ប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ សកម្មភាពរួមសំខាន់ៗរបស់ក្រុមការងារ ត្រូវបានលើកគម្រោងចំណាយរួម និងស្នើសុំការសម្រេចពីប្រធានគណៈកម្មាធិការរាជធានីដែលជាអភិបាលរាជធានី (សម្រាប់រាជធានី) និងប្រធានគណៈកម្មាធិការខេត្ត ដែលជាអភិបាលខេត្ត (សម្រាប់ខេត្តនីមួយៗ) ដើម្បីដាក់បញ្ចូលក្នុងកញ្ចប់ថវិការាជធានី ខេត្ត ប្រើប្រាស់ក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ក្រុមការងារ ត្រូវជួបប្រជុំទៀងទាត់ប្រចាំខែ ដើម្បីផ្លាស់ប្តូរព័ត៌មាន និងបទពិសោធន៍ ធ្វើរបាយការណ៍ និងលើកទិសដៅបន្ត និងចូលរួមកិច្ចប្រជុំនានាដែលរៀបចំដោយ គ.រ.ប.ជ ឬ គ.ខ.ប.ជ ។

**ប្រការ១៣.-**

គម្រោងថវិការួមប្រចាំឆ្នាំរបស់ គ.រ.ប.ជ ឬ គ.ខ.ប.ជ គឺជាឧបសម្ព័ន្ធនៃថវិកាប្រចាំឆ្នាំរបស់រាជធានី ខេត្ត ដោយដាក់បញ្ចូលថវិកាដែលត្រូវអនុវត្តភារកិច្ចប្រចាំខែរបស់មន្ត្រីទទួលបន្ទុកការងារនៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ និង ក្រុមការងារជំនាញអន្តរមន្ទីរ ស្ថាប័ន ដើម្បីធានាថាគ្រប់ផ្នែក មានថវិកាអនុវត្តសកម្មភាពជាប្រចាំ ដើម្បីធ្វើឱ្យសម្រេចទិសដៅក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

គណៈកម្មាធិការ និងលេខាធិការដ្ឋាន គ.ខ.ប.ជ ឬ គ.រ.ប.ជ អាចកៀរគរការចូលរួម ការគាំទ្រធនធាន ថវិកា និងកិច្ចសហការបន្ថែមទៀតពីបណ្តាអង្គការ ស្ថាប័ន និងសប្បុរសជននានាដើម្បីជាកម្លាំងសរុប និងធនធានសរុបក្នុងការអនុវត្ត និងធ្វើរបាយការណ៍ជូនអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ដើម្បីបានជ្រាប និងសរុបរាយការណ៍ជូនគណៈកម្មាធិការជាតិ គ.ជ.ប.ជ ។

**ប្រការ១៤.-**

គ.ខ.ប.ជ ឬ គ.រ.ប.ជ មានសិទ្ធិប្រើត្រា និងរូបសញ្ញាគណៈកម្មាធិការរាជធានី (សម្រាប់រាជធានី) ឬត្រា និងរូបសញ្ញាគណៈកម្មាធិការខេត្ត (សម្រាប់ខេត្តនីមួយៗ) តាមការកំណត់របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ( គ.ជ.ប.ជ) ។

**ប្រការ១៥.-**

លិខិតបទដ្ឋានទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទទួលបន្ទុកជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់អង្គភាព ស្ថាប័នដែលពាក់ព័ន្ធ គណៈអភិបាលរាជធានី ខេត្តត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០១៤

ឧបនាយករដ្ឋមន្ត្រី

ប្រធាន គ.ជ.ប.ជ

ស ខេង

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិគ.ជ.ប.ជ
- ក្រសួងមហាផ្ទៃ
- សាលារាជធានី-ខេត្ត
- ដូចប្រការ ១៦
- ឯកសារ កាលប្បវត្តិ

# ព្រះរាជក្រឹត្យ

នស/រកត/១១១៤/១២៩៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** តែងតាំងឯកឧត្តម ឧត្តមសេនីយ៍ឯក ថោង សំអាត អត្តលេខ ០៨៩៣ ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
**នរោត្តម សីហមុនី**

៣ រស. ១៤១១.១៣២០

លេខៈ១៣៤៧ស.ណ
សំណៅដែលមានត្រឹមត្រូវតាមច្បាប់ដើម សម្រាប់ចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី [illegible] ខែវិច្ឆិកា ឆ្នាំ២០១៤
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤

[illegible] សុខា

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៥១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិ និងមន្ត្រីរាជការ

---

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញអនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ៈ** តែងតាំងមុខតំណែងនាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងមន្ត្រីរាជការ ចំនួន ០៦រូប នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដូចមានរាយនាមខាងក្រោម ៖

១-លោកឧត្តមសេនីយ៍ទោ ខៀវ ចាន់រ៉ា អត្តលេខ ០៧៩៨ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

២-លោកឧត្តមសេនីយ៍ត្រី **យឹម ទិរៈ** — អគ្គលេខ ០៨៨៨ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

៣-លោកស្រីឧត្តមសេនីយ៍ត្រី **ប៊ុណ្ណា សំខាន់** — អគ្គលេខ ១២២៩៥ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

៤-លោកឧត្តមសេនីយ៍ត្រី **ស៊ុន រ៉ូ** — អគ្គលេខ ០១៤៨៦ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

៥-លោក **ចាន់ សុទណ្ណា** — ឋានន្តរស័ក្តិវរៈមន្ត្រីថ្នាក់លេខ៥ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

៦-លោកស្រី **រ៉ែន សិរីលក្ខិណា** — ឋានន្តរស័ក្តិអនុមន្ត្រីថ្នាក់លេខ១០ ជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៦៣៧ អនក្រ.បក

# អនុក្រឹត្យ

ស្តីពី

## ការតែងតាំងមុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** តែងតាំង លោក យ៉ែម ច័ន្ទណារុំ ឋានន្តរស័ក្តិមន្ត្រីថ្នាក់លេខ៩ជាអគ្គលេខាធិការរង អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ។

**មាត្រា២:** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៨ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងព្រះបរមរាជវាំង
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧៧០.អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងមន្ត្រីរាជការ និងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៦នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧៣អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ
- យោងតាមសំណើរបស់ក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១**: តែងតាំងមុខតំណែង មន្ត្រីរាជការស៊ីវិល និងនាយនគរបាលជាន់ខ្ពស់ចំនួន០៧រូប ដែលមានឋានៈនិងបុព្វសិទ្ធិស្មើប្រធាននាយកដ្ឋាន ដូចមានខាងក្រោម ៖

១- លោកឧត្តមសេនីយ៍ត្រី សុខ រស្មី អត្តលេខ ០៥៤៧៤ ជាមន្ត្រីជំនួយការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

២- លោកវរសេនីយ៍ឯក សុខ ឧុធថន អត្តលេខ ០៧០២៨ ជាប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

៣- លោកវរសេនីយ៍ឯក **ស្រី សាមឌី** អត្តលេខ ២៥៦៤១ ជាមន្ត្រីជំនួយការ
នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

៤- លោកវរសេនីយ៍ឯក **កែប សារឿន** អត្តលេខ ០៥៨៧៨ ជាមន្ត្រីជំនួយការ
នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

៥- លោកវរសេនីយ៍ឯក **លី តុងហ៊ុយ** អត្តលេខ ០៧៩០ ជាមន្ត្រីជំនួយការ
នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

៦- លោកវរសេនីយ៍ត្រី **កែវ សុវណ្ណារ៉ា** អត្តលេខ៧៣៥៧៥ ជាមន្ត្រីជំនួយការ
នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

៧- លោក **ចាន់ ចំណាន** ឋានន្តរស័ក្តអនុមន្ត្រីថ្នាក់លេខ១៤ ជាមន្ត្រីជំនួយការ
នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**មាត្រា ២ :** បទប្បញ្ញត្តទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាម៉ីខ្លួនដែលមានចែងក្នុង មាត្រា១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# របាយការណ៍សង្ខេបស្តីពី
# ការកសាងផែនការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
# ២០១៤-២០១៨

ផែនការសកម្មភាពជាតិបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្ម និង អាជីវកម្មផ្លូវភេទ ២០១១-២០១៣ បានប្រកាសដាក់ឲ្យប្រើប្រាស់ នៅថ្ងៃ ទី០៧ខែធ្នូ ឆ្នាំ២០១១ ។

ផែនការសកម្មភាពជាតិនេះ ត្រូវបានបង្កើតឡើង *"ដើម្បីពង្រឹងកិច្ចប្រឹងប្រែងក្នុងការអនុវត្តច្បាប់ រួមចំណែកក្នុងការផ្លាស់ប្តូរឥរិយាបថសង្គម លើកកម្ពស់ស្តង់ដារសិទ្ធិមនុស្ស ផ្តល់ភាពថ្លៃថ្នូរនិងគុណតម្លៃដល់ប្រជាជនខ្មែរ សិទ្ធិរបស់ស្ត្រី និង កាត់បន្ថយរាល់ទម្រង់នៃអំពើជួញដូរមនុស្សឱ្យបានច្រើន។"*

គោលដៅសំខាន់នៃផែនការ គឺលើកកម្ពស់ការចូលរួមកិច្ចសហប្រតិបត្តិការ សាមគ្គីភាព និងប្រើប្រាស់ធនធានទាំងឡាយឱ្យមានប្រសិទ្ធភាព ដើម្បីបង្ការទប់ស្កាត់នូវភាពរងគ្រោះរបស់ប្រជាពលរដ្ឋ ទាំងបុរស ស្ត្រី យុវវ័យ និង កុមារ ឱ្យរួចផុតពីការជួញដូរនិងការរំលោភបំពានគ្រប់រូបភាព ជាពិសេស ផ្តល់កិច្ច ការពារនិងឧបត្ថម្ភគាំទ្រជនរងគ្រោះ និង ពង្រឹងការអនុវត្តច្បាប់ក្នុងការលុបបំបាត់អំពើជួញដូរមនុស្ស ការរត់ ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទ ។

**១.ការវាយតម្លៃលើការអនុវត្តផែនការសកម្មភាពជាតិ ប.ជ.រ.ព.ភ. ឆ្នាំ ២០១១-២០១៣**

ការវាយតម្លៃលើការអនុវត្តផែនការសកម្មភាពជាតិ ត្រូវបានអនុវត្តដោយអ្នកវាយតម្លៃឯករាជ ពីខែកញ្ញា រហូតដល់ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយមានកិច្ចសហការនិងការគាំទ្របច្ចេកទេសដោយអង្គការវីនរ៉ក់អន្តរជាតិ និងមានការគាំទ្រផ្នែកថវិកាពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (USAID)។ ការវាយតម្លៃផ្តោតទៅលើចំណុចការអនុវត្តសកម្មភាពដែលបានកំណត់ទុកក្នុងយុទ្ធសាស្ត្រសំខាន់ៗទាំង០៥ គោលដៅទាំង០៦ និងលទ្ធផលរំពឹងទុកទាំង០៧ ។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងជាសំខាន់ ដើម្បីជួយដល់ការបង្កើតផែនការសកម្មភាពជាតិទី២ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៤-២០១៨។

បណ្តាក្រសួង មន្ទីរ ស្ថាប័ន អង្គការសង្គមស៊ីវិល អង្គការ អន្តរជាតិ ទីភ្នាក់ងារអង្គការសហប្រជាជាតិ ដែលមានសកម្មភាពពាក់ព័ន្ធនឹងគណៈកម្មាធិការ ក៏ដូចជាអាជ្ញាធររាជធានី ខេត្ត-ក្រុង មូលដ្ឋានឃុំ-សង្កាត់ មន្ត្រីអនុវត្តច្បាប់ ព្រមទាំងជនរងគ្រោះនិងងាយរងគ្រោះជាច្រើន បានចូលរួមផ្តល់ ព័ត៌មាន និងគំនិតយោបល់ ជាច្រើន ។ លទ្ធផលនៃការវាយតម្លៃនេះ ក៏ត្រូវបានដាក់ជូនមន្ត្រីជំនាញក្នុងរាជរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ រាជធានី ខេត្ត ដើម្បីពិនិត្យ ផ្តល់យោបល់ កែលម្អ និងផ្តល់ធាតុចូលបន្ថែមជាបន្តបន្ទាប់ក្នុងន័យកសាងឱ្យបាននូវផែនការសកម្មភាពរយៈពេលប្រាំឆ្នាំជំហានទី២ (២០១៤- ២០១៨) បានឆ្លើយតបទៅនឹងស្ថានភាពបច្ចុប្បន្នដែលមានការវិវត្តថ្មីៗ។

ខាងក្រោមនេះ គឺជាចំណុចសំខាន់ៗមួយចំនួននៃការវាយតម្លៃ ៖

១- ក្រសួង ស្ថាប័ននានា ទីភ្នាក់ងារអន្តរជាតិ និង អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជាច្រើនបានអនុវត្តយុទ្ធសាស្ត្រនិងវិធីសាស្ត្រមួយចំនួនរបស់ផែនការជាតិ រួមចំណែកក្នុងការសម្រេចបានលទ្ធផលរំពឹងទុកសំខាន់ៗទាំងប្រាំពីរ ដោយទទួលបានលទ្ធផលជាវិជ្ជមាន ។

២- ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីច្បាប់និងគោលនយោបាយដែលបានបង្កើតឡើងក្នុងប្រទេសកម្ពុជា ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និង រូបភាពកេងប្រវ័ញ្ចផ្សេងៗ កើនឡើងគួរឲ្យកត់សម្គាល់ ជា

ពិសេស គឺ អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មពលកម្មក្នុងបរិបទនៃការធ្វើចំណាកស្រុកឆ្លងដែន តែវិធីសាស្ត្រជាច្រើនបានផ្តោតជាសំខាន់ទៅលើតែការលើកកម្ពស់ចំណេះដឹងប៉ុណ្ណោះ តែមិនសូវបានផ្តោតលើការផ្លាស់ប្តូរឥរិយាបថឡើយ ។

៣- សហគមន៍ បានមើលឃើញថា មន្ត្រីអនុវត្តច្បាប់បានបំពេញតួនាទីរបស់ខ្លួនបានកាន់តែប្រសើរ កត្តានេះធ្វើឱ្យប្រជាជនកាន់តែមានទំនុកចិត្តលើមន្ត្រីទាំងនេះ ។ ជាក់ស្តែង អាជ្ញាធរមូលដ្ឋាននិងជនរងគ្រោះបានរាយការណ៍ ដោយផ្ទាល់អំពីករណីជួញដូរមនុស្សដល់មន្ត្រីអនុវត្តច្បាប់កាន់តែច្រើន ។ តែក៏មានប្រជាពលរដ្ឋខ្លះបានសម្តែងពីអារម្មណ៍មិនពេញចិត្តចំពោះការផ្តន្ទាទោស ។

៤- កិច្ចសហប្រតិបត្តិការរវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា, នគរបាល, ក្រុមប្រឹក្សាច្បាប់ និង អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ មានលក្ខណៈជាប្រព័ន្ធ និងមានភាពល្អប្រសើរក្នុងការផ្តល់នូវសេវាផ្លូវច្បាប់ និងជំនួយចិត្ត សាស្ត្រដែលជាតម្រូវការចាំបាច់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និង ជួញ ដូរផ្លូវភេទ ហើយបាននិងកំពុងឆ្លើយតបចំបញ្ហា និងបានសម្របសម្រួលដោះស្រាយដោយអនុវត្តតាមបទដ្ឋានអប្បបរមានៃការការពារ និងផ្តល់ជំនួយគាំទ្រដល់ជនរងគ្រោះ។

៥- គុណប្រយោជន៍ប្រសើរបំផុត គឺក្រសួងពាក់ព័ន្ធមួយចំនួន ដូចជា ក្រសួងមហាផ្ទៃ, កងរាជអាវុធហត្ថ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងកិច្ចការនារី និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតឱ្យមាននាយកដ្ឋាន ឬការិយាល័យជាក់លាក់របស់ខ្លួន ដើម្បីទទួលខុសត្រូវផ្ទាល់លើការប្រឆាំងអំពើជួញដូរមនុស្សនិងកិច្ចអន្តរាគមន៍ ដែលជួយសម្របសម្រួលឱ្យមានកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធរវាងភាគីពាក់ព័ន្ធជាតិនិងអន្តរជាតិ និងការអនុវត្តសកម្មភាពនៅកម្រិតមូលដ្ឋាន ។

៦- គ្រប់តួអង្គ និងភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់ យល់ឃើញថា អំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទ គឺជាបញ្ហាមួយដ៏ធំដែលមិនអាចដោះស្រាយដោយឡែកៗពីគ្នាបានឡើយ ពោលគឺត្រូវការចូលរួមសហប្រតិបត្តិការពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ហើយគណៈកម្មាធិការជាតិ បានដើរតួនាទីសំខាន់ក្នុងការជួយលើកកម្ពស់ការសម្របសម្រួលរវាងភាគីពាក់ព័ន្ធខុសៗគ្នា ឲ្យអាចធ្វើការជាមួយគ្នាបានយ៉ាងល្អប្រសើរ ។ អង្គការមិនមែនរដ្ឋាភិបាលបានវាយតម្លៃលើបញ្ហាប្រឈមក្នុងកិច្ចសហការ និងកំពុងសិក្សាអំពីការធ្វើឱ្យមានឥទ្ធិពលជាវិជ្ជមាន និងមានឆន្ទៈផ្តល់ការគាំទ្របន្ថែមទៀតឱ្យកាន់តែមានប្រសិទ្ធភាពលើការកសាង និងពង្រឹងទំនាក់ទំនងសម្របសម្រួលកិច្ចសហប្រតិបត្តិការ។

៧- ការអនុវត្តផែនការជាតិឆ្នាំ២០១១-២០១៣ មានរយៈពេលខ្លី គឺអនុវត្តបានត្រឹមតែ១៨ខែមុនពេលធ្វើការវាយតម្លៃប៉ុណ្ណោះ (ដាក់ឱ្យប្រើប្រាស់ផ្លូវការក្នុងខែកុម្ភៈឆ្នាំ២០១២) នេះជាហេតុធ្វើឱ្យការវាយតម្លៃ ពិបាករកឱ្យឃើញភាពប្រែប្រួល ។

៨- ថវិកាដែលលេខាធិការដ្ឋានជាតិ និងខេត្តមួយចំនួនបានទទួលសម្រាប់អនុវត្តផែនការសកម្មភាពជាតិប្រឆាំងអំពើជួញដូរមនុស្ស មានកម្រិត និងត្រូវបានប្រើប្រាស់សម្រាប់តែការងាររដ្ឋបាលនិងសកម្មភាពមួយចំនួនតូចប៉ុណ្ណោះ ។ គោលបំណងក្នុងការប្រើប្រាស់ថវិកាជាតិ ដើម្បីអនុវត្តផែនការសកម្មភាពជាតិ របស់ក្រសួងបច្ចេកទេសពាក់ព័ន្ធ មិនទាន់អាចអនុវត្តបានពេញលេញតាមការរំពឹងទុកនៅឡើយ ដោយសារភាពស្មុគស្មាញនៃនីតិវិធី និងរយៈពេល និងការរៀបចំផែនការថវិកាមិនស្របតាមពេលវេលាកំណត់ ។

៩- ទោះបីជាមានច្បាប់ គោលនយោបាយ និងអនុស្សរណៈយោគយល់គ្នារវាងព្រះរាជាណាចក្រ កម្ពុជានិងប្រទេសពាក់ព័ន្ធមួយចំនួនសម្រាប់ដោះស្រាយបញ្ហាអំពើជួញដូរក៏ដោយ ក៏ច្បាប់ គោលនយោបាយ និង អនុស្សរណៈមួយចំនួនមិនមានលក្ខណៈគ្រប់គ្រាន់ មិនច្បាស់លាស់ និង ខ្វះខាតគោលការណ៍ណែនាំអនុវត្ត ឬ មិនត្រូវបានអនុវត្ត

ឱ្យបានស៊ីសង្វាក់គ្នា ឬមិនបានសហការគ្នាគ្រប់គ្រាន់ ដែលជាហេតុធ្វើឱ្យរាំងស្ទះដល់កិច្ចប្រឹងប្រែងក្នុងការដោះស្រាយបញ្ហាឲ្យមានប្រសិទ្ធភាព។

## ២- ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការកសាងផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជំហានទី២ (ឆ្នាំ២០១៤-២០១៨)

លទ្ធផលនៃការវាយតម្លៃ ជាបទពិសោធន៍ និងមេរៀនដែលទទួលបានពីការអនុវត្តផែនការសកម្មភាពជាតិឆ្នាំ ២០១១-២០១៣ ត្រូវបានប្រើជាមូលដ្ឋានសម្រាប់ធ្វើសេចក្តីព្រាងក្របខណ្ឌយុទ្ធសាស្ត្រ និង ផែនការសកម្មភាពជាតិ តំណាក់កាលទី២ រយៈពេលប្រាំឆ្នាំ សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សសម្រាប់អនុវត្តពីឆ្នាំ២០១៤-២០១៨។

ការវាយតម្លៃនេះ បានរកឃើញនូវចំណុចខ្វះខាតនៃយន្តការ ដែលត្រូវការរៀបចំកែសម្រួលរចនាសម្ព័ន្ធ តួនាទីភារកិច្ចរបស់គ្រប់ផ្នែកពាក់ព័ន្ធ នៅគ្រប់ថ្នាក់ និងត្រូវធ្វើការសម្របសម្រួលប្រមូលផ្តុំនូវគ្រប់ការចូលរួម កិច្ចខិតខំប្រឹងប្រែង ឲ្យស៊ីសង្វាក់គ្នា និងឲ្យក្លាយជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុប ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។

ក្របខណ្ឌយុទ្ធសាស្ត្រនេះគឺជាជំហានដ៏សំខាន់ក្នុងដំណើរការអនុវត្តយុទ្ធសាស្ត្រទូលំទូលាយ សម្រាប់ផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរគ្រប់រូបភាព រយៈពេលប្រាំឆ្នាំបន្ត ដោយធានានិរន្តរភាពនៃយន្តការដំណើរការ និង អន្តរាគមន៍ឱ្យមានការឯកភាពគ្នា។

ដោយមានការដឹកនាំនិងសម្របសម្រួលយ៉ាងសកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់របស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ ក្រសួងស្ថាប័នពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាល ថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ បានរួមគ្នាផ្តល់គំនិត យោបល់ ទិន្នន័យ និងគំនិតផ្តួចផ្តើមជាច្រើន ហើយទស្សនៈរបស់សង្គមស៊ីវិល និង អ្នកដែលទទួលរងគ្រោះក្នុងឧក្រិដ្ឋកម្មជួញដូរ និងអាជីវកម្មផ្លូវភេទ ភាគីពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍន៍ អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិលក្នុងស្រុក ក៏ត្រូវបានទទួលយក និងដាក់បញ្ចូលផងដែរ ។

### ២.១- ទស្សនវិស័យនៃផែនការ

*"ព្រះរាជាណាចក្រកម្ពុជា ជាសង្គមមួយមានសន្តិភាពពេញលេញ មានសមភាព និង ការអភិវឌ្ឍប្រកបដោយចីរភាព គ្មានអំពើជួញដូរ កេងប្រវ័ញ្ច និង ការធ្វើអាជីវកម្មលើមនុស្ស"* ។

### ២.២- គុណតម្លៃស្នូលនៃផែនការសកម្មភាពជាតិ

#### ២.២.១- ភាពជាម្ចាស់របស់រាជរដ្ឋាភិបាលលើផែនការសកម្មភាពជាតិ

រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាសកម្មភាពអាទិភាពមួយដែលត្រូវផ្តោតយកចិត្តទុកដាក់ ដោយហេតុថា វាបានធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរ ដល់កម្លាំងពលកម្មដែលត្រូវប្រើប្រាស់សម្រាប់ការអភិវឌ្ឍន៍ជាតិ និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ។ រាជរដ្ឋាភិបាលមានភារកិច្ចដោះស្រាយតម្រូវការធនធានហិរញ្ញវត្ថុដើម្បីអនុវត្តផែនការសកម្មភាពជាតិនេះដោយធានាថា យន្តការគ្រប់ថ្នាក់មានលទ្ធភាពអនុវត្តភារកិច្ច និងអាចជំរុញឱ្យយុទ្ធសាស្ត្រនិងសកម្មភាពទាំងឡាយអាចអនុវត្តបានតាមការគ្រោងទុក ប្រកបដោយការទទួលខុសត្រូវរបស់ក្រសួងជំនាញនីមួយៗ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

#### ២.២.២- គោលការណ៍សិទ្ធិមនុស្សជាមូលដ្ឋាន

ការការពារសិទ្ធិនិងសុខុមាលភាពរបស់ប្រជាជនកម្ពុជាទាំងអស់ ជាពិសេសសិទ្ធិជនរងគ្រោះឬជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស គឺជាស្នូលនៃកិច្ចប្រឹងប្រែងទាំងឡាយក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ សិទ្ធិទាំងនោះនឹងត្រូវបានបង្ហាញតាមរយៈលទ្ធភាពទទួលបានព័ត៌មាន ការផ្តល់នូវជំនួយផ្នែកសង្គម សេវាកម្ម រួម

ទាំងការគាំទ្រផ្លូវចិត្ត ជំនួយផ្នែកច្បាប់ ការធ្វើកោសល្យវិច័យ ការថែទាំវេជ្ជសាស្ត្រ ការស្តារនីតិសម្បទា ការគាំទ្រការធ្វើសមាហរណកម្ម ជំនួយគាំទ្រផ្នែកសេដ្ឋកិច្ច ជំនាញ មុខរបរ និង ការធ្វើសមាហរណកម្មរយៈពេលវែង ជាដើម។

**២.២.៣- កម្មវិធីផ្អែកលើគោលការណ៍យេនឌ័រជាមូលដ្ឋាន**

ការប្រើប្រាស់ទិន្នន័យយេនឌ័រ គឺមិនមែនសម្រាប់តែបង្ហាញអំពីទំហំ និងឥទ្ធិពលនៃអំពើហិង្សាលើស្ត្រីប៉ុណ្ណោះទេ តែថែមទាំងផ្តោតការយកចិត្តទុកដាក់ ទៅលើមនុស្សទាំងអស់ ទោះជាបុរសឬស្ត្រី កុមារ យុវវ័យ ឬមនុស្សចាស់ ត្រូវទទួលបានសិទ្ធិជាសាកលក្នុងការរស់នៅដោយស្មើភាព ដោយមិនមានការទទួលរងអំពើហិង្សា ការប្រមាថមាក់ងាយ ឬការរំលោភបំពាន ទោះជាក្នុងកាលៈទេសៈណាក៏ដោយ។ ទាំងរាជរដ្ឋាភិបាល ក៏ដូចជាសង្គមស៊ីវិល គឺខិតខំដើម្បី<u>លុបបំបាត់ទស្សនៈ</u> ដែលថា៖ "ការជួញដូរមនុស្ស ការធ្វើអាជីវកម្មពលកម្ម និង ការធ្វើអាជីកម្មលើផ្លូវភេទ គឺជាធម្មជាតិរបស់មនុស្សក្នុងសង្គម ដែលតែងតែកើតមានតាំងពីយូរលង់មកហើយនិងមិនអាចលុបបំបាត់បាន" ។

*ការពិត អាចលុបបំបាត់បាន ឬមិនបាន គឺអាស្រ័យដោយឆន្ទៈរបស់មនុស្សក្នុងសង្គម និងគ្រប់ស្ថាប័ន ។ ដូច្នេះ បញ្ហាសំខាន់ គឺការផ្លាស់ប្តូរទស្សនៈនិងឥរិយាបថសង្គម ឲ្យមានសីលធម៌ គុណធម៌ ទទួលស្គាល់នូវគុណតម្លៃរបស់មនុស្ស និងមានការគោរពសិទ្ធិគ្នាទៅវិញទៅមក ដោយមិនរើសអើង ។*

**២.២.៤- មានការចូលរួមយ៉ាងសកម្មពីសង្គមស៊ីវិលនិងអ្នកពាក់ព័ន្ធ**

គណៈកម្មាធិការជាតិទទួលស្គាល់ថា អង្គការសង្គមស៊ីវិលដ៏ច្រើនលើសលប់នៅកម្ពុជា អាចជួយធ្វើឱ្យមានភាពប្រសើរឡើងនូវអន្តរាគមន៍ពាក់ព័ន្ធនឹងការបង្ការ ទប់ស្កាត់ ការការពារ និងការផ្តន្ទាទោសបទឧក្រិដ្ឋ ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ សេវាច្បាប់និងចិត្តសាស្ត្រ ក៏ដូចជាសេវាអនុវត្តច្បាប់សម្រាប់ជនរងគ្រោះនៃការធ្វើអាជីវកម្ម និងការរំលោភបំពាន នៅពេលដែលសង្គមស៊ីវិល ដើរតួនាទីធ្វើជាដៃគូក្នុងការអនុវត្តផែនការជាតិ ឆ្ពោះទៅកាន់ការធ្វើឲ្យសម្រេចគោលដៅរួម ។

**២.២.៥- សមាហរណកម្មពហុវិស័យ**

គណៈកម្មាធិការជាតិលើកទឹកចិត្តចំពោះកិច្ចសហការ ការសម្របសម្រួល និង ភាពជាដៃគូនៅគ្រប់ កម្រិត ។ ស្ថាប័នរាជរដ្ឋាភិបាលនឹងសម្របសម្រួលបង្កើតភាពជាដៃគូជាមួយភាគីពាក់ព័ន្ធចម្រុះ ដូចជា សាស្ត្រាចារ្យ អង្គការសិក្សាស្រាវជ្រាវ អង្គការសង្គមស៊ីវិល អង្គការដៃគូមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិ ស្ថាប័នក្នុងវិស័យសាសនា វិស័យឯកជន ម្ចាស់ជំនួយទ្វេភាគី និង ពហុភាគីផ្សេងៗទៀត ទាំងនៅថ្នាក់ ជាតិ ថ្នាក់តំបន់ ក៏ដូចអន្តរជាតិ ដើម្បីទទួលបានការសម្របសម្រួលល្អបំផុតសម្រាប់យុទ្ធវិធីគ្រប់ជ្រុងជ្រោយពហុវិស័យ។

**២.២.៦.- ការត្រួតពិនិត្យ ការវាយតម្លៃជាប្រព័ន្ធ និង និរន្តរភាព**

ការត្រួតពិនិត្យ និងការវាយតម្លៃ គឺជាសមាសធាតុដ៏សំខាន់មួយនៃផែនការសកម្មភាពជាតិ។ អគ្គលេខាធិការដ្ឋាននៃ គណៈកម្មាធិការជាតិនឹងទទួលបន្ទុកអនុវត្ត ដោយសហការជាមួយអ្នកជំនាញនិងស្ថាប័នពាក់ព័ន្ធ ហើយលេខាធិការដ្ឋាននៃគណៈកម្មាធិការរាជធានី ខេត្ត នឹងបន្តត្រួតពិនិត្យលើការអនុវត្តផែនការសកម្មភាពជាតិ ផែនការសកម្មភាពរាជធានី ខេត្ត និង ចែករំលែកជាទៀងទាត់នូវលទ្ធផលនៃការត្រួតពិនិត្យសំខាន់ៗដែលជួយដល់ការរៀបចំកម្មវិធីការងារបន្ត។

ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃដែលរឹងមាំមួយសម្រាប់កំណត់អំពីភាពរីកចម្រើននៃការអនុវត្ត នឹងត្រូវបានបង្កើត ឡើងដោយមានសូចនាករគ្រប់គ្រាន់សម្រាប់វាស់ស្ទង់ផលប៉ះពាល់ សមិទ្ធផល និង មេរៀនជាបទពិសោធន៍ដើម្បីបង្កើនប្រសិទ្ធភាពនៃកម្មវិធីបង្ការ ការពារ និង ឆ្លើយតបក្នុងពេលអនាគត។

## ២.៣- គោលដៅរួម និងគោលបំណង

ផែនការសកម្មភាព មានគោលដៅ រួមបញ្ចូលរាល់កិច្ចខិតខំប្រឹងប្រែងគ្រប់ផ្នែក គ្រប់វិស័យពាក់ព័ន្ធ ដើម្បី

ដោះស្រាយនិងលុបបំបាត់រាល់ទម្រង់នៃអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និង ការធ្វើអាជីវកម្មផ្លូវភេទដែលកើតមាននៅក្នុងប្រទេសកម្ពុជា និង ទៅលើប្រជាជនកម្ពុជាដែលនៅទីណាក៏ដោយ។

*គោលបំណងសំខាន់ គឺដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការបង្ការទប់ស្កាត់បទល្មើសជួញដូរមនុស្ស អំពើកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាព ការជួយជនរងគ្រោះ ការអនុវត្តច្បាប់ ការផ្តន្ទាទោសជនល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទប្រកបដោយភាពយុត្តិធម៌ ។*

**២.៤- យុទ្ធសាស្ត្រនៃផែនការសកម្មភាពជាតិ ជាអាទិភាពចំនួនបួន គឺ ៖**

យុទ្ធសាស្ត្រទី១ ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និង លើកកម្ពស់សហប្រតិបត្តិការ

យុទ្ធសាស្ត្រទី២ លើកកម្ពស់ការបង្ការ ការទប់ស្កាត់

យុទ្ធសាស្ត្រទី៣ ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឱ្យឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

យុទ្ធសាស្ត្រទី៤ ការពារជនរងគ្រោះគ្រប់ភេទនិងគ្រប់វ័យ ព្រមទាំងផ្តល់សេវាគាំទ្រសមស្របប្រកបដោយគុណភាព ។

ដើម្បីធ្វើឲ្យសម្រេចយុទ្ធសាស្ត្រទាំងបួន សកម្មភាពសំខាន់ៗចំនួន១៣៣ ត្រូវបានបង្កើតឡើង និងចងក្រងជា ១០ កម្រងសកម្មភាព ។

**យុទ្ធសាស្ត្រទី១ : ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និង លើកកម្ពស់កិច្ចសហប្រតិបត្តិការ**

មានលទ្ធផលរំពឹងទុក ចំនួន០៣ ៖

១.១- កែលម្អ និងពង្រឹងយន្តការជាតិសម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឲ្យមានការចូលរួមកាន់តែទូលំទូលាយនិងមានធនធានគ្រប់គ្រាន់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តច្បាប់ គោលនយោបាយ និង លើកកម្ពស់កិច្ចសហប្រតិបត្តិការ ជាតិនិងអន្តរជាតិ ។

១.២- អនុស្សរណៈនៃការយោគយល់គ្នាឬកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី លិខិតុបករណ៍គតិយុត្ត ដទៃទៀតពាក់ព័ន្ធនឹងរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មពលកម្មនិងផ្លូវភេទ ត្រូវបានអនុវត្តដោយភាគីពាក់ព័ន្ធប្រកបដោយការទទួលខុសត្រូវនិងមានលទ្ធផលល្អ ។

១.៣- ច្បាប់ គោលនយោបាយ ផែនការរបស់ជាតិនិងអន្តរជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ត្រូវបានចូលរួមអនុវត្ត និង តាមដានត្រួតពិនិត្យអំពីប្រសិទ្ធភាព និងប្រសិទ្ធផល រកភាពខ្វះចន្លោះដើម្បីបំពេញបន្ថែមនិងជំរុញការចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

*ក្នុងយុទ្ធសាស្ត្រទី១នេះ: មានកម្រងសកម្មភាពចំនួន០៣ ដែលឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុកទាំង០៣ មានសកម្មភាពធំៗសរុបចំនួន ៤៧ ។*

**យុទ្ធសាស្ត្រទី២ : លើកកម្ពស់ការបង្ការ ការទប់ស្កាត់**

**មានលទ្ធផលរំពឹងទុកចុងក្រោយចំនួន០២**

២.១- យុទ្ធសាស្ត្របង្ការ ការទប់ស្កាត់ត្រូវបានរៀបចំនិងអនុវត្ត ដើម្បីដោះស្រាយតម្រូវការនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយផ្តោតលើការផ្លាស់ប្តូរទស្សនៈ និង ឥរិយា- បថរបស់បុគ្គលនិងសហគមន៍។

២.២- តាមដាននិងគ្រប់គ្រងដំណើរការនៃការធ្វើចំណាកស្រុករបស់ពលករ ដើម្បីការពារ និង លើកកម្ពស់សុវត្ថិភាព ការគោរពសិទ្ធិ ការទទួលបានផលប្រយោជន៍ស្របច្បាប់របស់ពលករចំណាកស្រុកនៅគ្រប់តំណាក់កាលនៃការធ្វើទេសន្តរប្រវេសន៍ ។

*ក្នុងយុទ្ធសាស្ត្រទី២នេះ: មានកម្រងសកម្មភាពចំនួន០២ ដែលឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុក០២ មានសកម្មភាពធំៗ ចំនួន ២៧ ។*

**យុទ្ធសាស្ត្រទី៣:ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌឱ្យឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស**

មានលទ្ធផលរំពឹងទុក ចំនួន ០៣

៣.១- ចំណេះដឹងនិងសមត្ថភាពក្នុងការប្រើប្រាស់លិខិតុបករណ៍គតិយុត្តក្នុងស្ថាប័នតុលាការសម្រាប់ការជំនុំជម្រះករណីនៃអំពើជួញដូរមនុស្ស កាន់តែប្រសើរឡើង។

៣.២- ការសម្របសម្រួលរវាងស្ថាប័នអនុវត្តច្បាប់ ស្ថាប័នអយ្យការ និង វិស័យសេវាសង្គម ទទួលបានលទ្ធផលល្អ ក្នុងការស៊ើបអង្កេតប្រមូលពត៌មាន ការជំនុំជម្រះក្តីករណីនៃអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មពលកម្មលើមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ។

៣.៣. វិធានការឆ្លើយតប ការគ្រប់គ្រងករណី និង ប្រព័ន្ធរាយការណ៍តាមរយៈមន្ត្រីជំនាញអនុវត្តច្បាប់និងភ្នាក់ងារដទៃ មានការឯកភាព ជាប្រព័ន្ធ សម្រាប់ការប្រើប្រាស់។

*ក្នុងយុទ្ធសាស្ត្រទី៣ មានកម្រងសកម្មភាពចំនួន០៣ ដែលឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុកទាំង០៣ ដែលមានសកម្មភាពធំៗ ចំនួន ៣៨ ។*

**យុទ្ធសាស្ត្រទី៤ :** **ការពារជនរងគ្រោះគ្រប់ភេទនិងគ្រប់វ័យ ព្រមទាំងផ្តល់សេវាគាំទ្រសមស្របប្រកបដោយគុណភាព**

ដោយផ្តោតការយកចិត្តទុកដាក់លើការកំណត់អត្តសញ្ញាណជនល្មើសនិងជនរងគ្រោះ ការស្តារនីតិ-សម្បទា ការធ្វើមាតុភូមិនិវត្តន៍ ការធ្វើសមាហរណកម្ម និង ការអភិវឌ្ឍនជនរងគ្រោះនិងសហគមន៍គាំទ្រ ពិសេសលើស្ត្រីនិងកុមារ

មានលទ្ធផលរំពឹងទុកចំនួន ០២ ៖

៤.៤.១- ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ការជួញដូរពលកម្មនិងផ្លូវភេទ ត្រូវបានសង្គ្រោះ ធ្វើមាតុភូមិនិវត្តន៍ ស្តារនីតិសម្បទា ធ្វើសមាហរណកម្ម និង ផ្តល់លទ្ធភាពពេញលេញដល់ ជនរងគ្រោះគ្រប់ភេទ និង អាយុឱ្យទទួលបានសេវាដែលចាំបាច់តាមតម្រូវការ។

៤.៤.២- កិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់សេវារដ្ឋាភិបាលនិងមិនមែនរដ្ឋាភិបាល កាន់តែល្អប្រសើរក្នុងការផ្តល់សេវាគាំទ្រដល់ជនរងគ្រោះប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និង ទាន់ ពេលវេលា។

*ក្នុងយុទ្ធសាស្ត្រទី៤ នេះ មានកម្រងសកម្មភាពចំនួន០២ ដែលឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុកទាំង០២ និងមានសកម្មភាពធំៗ ចំនួន ២២ ។*

## ៥- ការត្រួតពិនិត្យនិងការវាយតម្លៃ

១- យន្តការសម្រាប់ការតាមដានត្រួតពិនិត្យការអនុវត្តផែនការជាតិ ត្រូវបានបង្កើតឡើងជាផ្លូវការ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធ

២- សមត្ថភាពមន្ត្រីអនុវត្តគ្រប់ផ្នែក គ្រប់ថ្នាក់ត្រូវបានពង្រឹងជាប្រចាំ

៣- ឧបករណ៍សម្រាប់ការតាមដានត្រួតពិនិត្យត្រូវបានបង្កើតឡើងនិងប្រើប្រាស់

៤- ទិន្នន័យដែលប្រមូលបាន ត្រូវធ្វើការវាយតម្លៃនិងផ្សព្វផ្សាយ

៥- របាយការណ៍លទ្ធផលនៃការអនុវត្តផែនការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងចេញផ្សាយប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និង ប្រចាំឆ្នាំ ដើម្បីប្រៀបធៀបលទ្ធផលនិងបទល្មើស ជួញដូរមនុស្ស។

## សន្ទរកថា

## ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
## និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
## ក្នុងឱកាសបើកកម្មវិធីប្រកាស
## គណៈកម្មាធិការជាតិ រចនាសម្ព័ន្ធ និងផែនការ យុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ឆ្នាំ២០១៤-២០១៨

ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១៥

សាលប្រជុំក្រសួងមហាផ្ទៃ

**សូមគោរព!**

**-ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវសមាជិករាជរដ្ឋាភិបាល និង សមាជិកគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ**

**-ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត តំណាងបេសកកម្មការទូត នៃប្រទេសជាមិត្ត ប្រចាំនៅកម្ពុជា**

**-ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អភិបាលរាជធានី-ខេត្ត អគ្គស្នងការ អគ្គនាយក អគ្គបញ្ជាការ និងថ្នាក់ដឹកនាំនាយកដ្ឋានជំនាញតាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងលោកលោកស្រី នាងកញ្ញាតំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ទីភ្នាក់ងារ អង្គការសហប្រជាជាតិ និង សមាជិក សមាជិកានៃអង្គពិធីទាំងអស់ជាទីរាប់អាន !**

ក្នុងឱកាសដ៏នក្ខត្តឫក្សនេះ ក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខ្ញុំសូមសម្តែងនូវសេចក្តីសោមនស្សរីករាយ ក្នុងពិធីប្រកាសជាផ្លូវការ នូវគណៈកម្មាធិការជាតិគណៈ កម្មាធិការថ្នាក់ក្រោមជាតិ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ព្រមទាំងរចនាសម្ព័ន្ធនៃយន្តការគ្រប់ថ្នាក់ ផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ ២០១៤- ២០១៨ ។

ខ្ញុំសូមសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលអញ្ជើញចូលរួមក្នុងពិធីប្រកាសជាផ្លូវការ គណៈកម្មាធិការជាតិ គណៈកម្មាធិការថ្នាក់ក្រោមជាតិ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា នាឱកាសនេះបញ្ជាក់ឲ្យឃើញអំពីការយកចិត្តទុកដាក់ខ្ពស់ និងការចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងទៅនឹងអំពើជួញដូរមនុស្ស ។

ឯកឧត្តម! លោកជំទាវ! អស់លោក លោកស្រី!

ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងក្នុងរាជរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងទីភ្នាក់ងារអង្គការសហប្រជាជាតិទាំងអស់ ដែលបានរួមគ្នាកន្លងមកក្នុងកិច្ចសហប្រតិបត្តិការលើការងារ និងការរៀបចំជាច្រើន រហូតបានសម្រេចជាស្ថាពរ ។ ខ្ញុំមានក្តីសង្ឃឹមជឿជាក់ថា គណៈកម្មាធិការជាតិនេះ នឹងបន្តដំណើរការតាមតួនាទី និងភារកិច្ចដែលបានកំណត់យ៉ាងល្អប្រសើរ អាស្រ័យដោយមានការចូលរួមយ៉ាងសកម្ម ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាសមាជិក សមាជិកាទាំងអស់ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ថ្នាក់ ។ មានតែការរួមកម្លាំងសហការ និងការឯកភាពគ្នាប៉ុណ្ណោះទេ ទើបអាចយកឈ្នះលើបទល្មើសគួរឲ្យស្អប់ខ្ពើមនេះបាន។ អំពើជួញដូរមនុស្ស គឺជាបទល្មើសឧក្រិដ្ឋ មួយ ក្នុងចំណោមឧក្រិដ្ឋកម្មឆ្លងដែន ដែលប្រទេសនានាកំពុងតែប្រឈមមុខនៅក្នុងប្រមាណជាងពីរទសវត្សរ៍ចុងក្រោយនេះ ។ អំពើជួញដូរមនុស្សត្រូវបានគេចាត់ទុកថាជាទាសភាពសម័យទំនើបដែលមានចរិតស្មុគ្រស្មាញ ប្រកបដោយល្បិចកល ពាក់ព័ន្ធទៅនឹងរបត់

នៃផ្នត់គំនិត ចិត្តសាស្ត្រសង្គម ការរីកចម្រើននៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា ការវិវត្តន៍នៃសេដ្ឋកិច្ច នយោបាយជាតិ និងអន្តរជាតិជាដើម ដែលត្រូវការជាចាំបាច់នូវការប្តេជ្ញាចិត្តរួមគ្នា ដើម្បីរិះរកវិធានការ ដែលមានប្រសិទ្ធិភាពក្នុងការបង្ការ-ទប់ស្កាត់ និងបង្ក្រាបរាល់បទល្មើសពាក់ព័ន្ធ បទល្មើសដែលមានការចាត់តាំង និងឧក្រិដ្ឋជន ដើម្បីកាត់បន្ថយឈានទៅលុបបំបាត់ឲ្យបាន ។

ឧក្រិដ្ឋជនធ្វើសកម្មភាពបទល្មើសដោយប្រើប្រាស់គ្រប់មធ្យោបាយ និងវិធីសាស្ត្រគ្រប់រូបភាព ក្នុងគោលបំណងទុច្ចរិត ដើម្បីកេងប្រវ័ញ្ចយកផលប្រយោជន៍ពីជនរងគ្រោះ បើទោះបីជាមានច្បាប់ដាក់ទោសទណ្ឌធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏ឧក្រិដ្ឋជនមិនញញើតនឹងធ្វើសកម្មភាពឡើយ ឲ្យតែគេអាចទាញយកផលចំណេញបាន គេនឹងធ្វើដោយមិនគិតពីការឈឺចាប់ ឬក្តីវិនាសអន្តរាយរបស់មនុស្សណាម្នាក់ ឬប្រទេសជាតិណាមួយឡើយ ជាក់ស្តែងកន្លងមកមានជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានរងគ្រោះធ្ងន់ធ្ងរជាបន្តបន្ទាប់។ .

កន្លងមក ព្រះរាជាណាចក្រកម្ពុជា បានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើបញ្ហានេះ ហើយក្រសួងស្ថាប័នក្នុងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិជាច្រើន ក៏បាន និងកំពុងតែធ្វើការងារយ៉ាងសកម្ម ពាក់ព័ន្ធទៅនឹងការបង្ការទប់ស្កាត់ ការបង្ក្រាប ការជួយជនរងគ្រោះ និងការផ្តន្ទាទោសជនល្មើស ។ យើងមានច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តជាច្រើន ដែលត្រូវបានជំរុញការអនុវត្ត និងតាមដានយ៉ាងយកចិត្តទុកដាក់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងនោះដែរយើងបានគិតគូរបំពេញបន្ថែមភាពខ្វះចន្លោះក្នុងក្របខណ្ឌច្បាប់ និងក្របខណ្ឌនៃការអនុវត្ត ដើម្បីធានាឲ្យបានការឆ្លើយតបក្នុងការប្រយុទ្ធប្រឆាំងទៅនឹងអំពើជួញដូរមនុស្ស ។

ទន្ទឹមនឹងកិច្ចខិតខំប្រឹងប្រែងនេះ យើងបានសង្កេតឃើញថា បទល្មើសនៅតែកើតមាន ហើយប្រជាពលរដ្ឋនៅតែបន្តរងគ្រោះជាបន្តបន្ទាប់ ដែលភាពរងគ្រោះមួយចំនួនធំ គឺកើតឡើងនៅក្រៅប្រទេស ក្នុងពេលដែលប្រជាពលរដ្ឋធ្វើចំណាកស្រុក ជាពិសេស ការធ្វើទេសន្តរប្រវេសន៍ដោយមិនមានច្បាប់ត្រឹមត្រូវ ទាំងការស្វែងរកការងារ ទាំងការស្វែងរកគូស្រករនៅក្រៅប្រទេស ។ ភាពស្មុគស្មាញនៃបទល្មើសជួញដូរមនុស្ស បានធ្វើឲ្យការអនុវត្តច្បាប់ជួបការលំបាក ក្នុងការវិភាគរកធាតុផ្សំនៃអំពើល្មើសដើម្បីបង្ក្រាប និងបានអូសបន្លាយឲ្យជនល្មើសអាចរួចផុតពីការផ្តន្ទាទោស បើទោះបីជាមើលឃើញថា ជនទាំងនោះជាអ្នកបង្កឬអូសទាញឲ្យជនរងគ្រោះជួបនូវគ្រោះមហន្តរាយដោយការរំលោភបំពាន កេងប្រវ័ញ្ច ការប្រើហិង្សាបង្ខិតបង្ខំ ប្រៀបបាននឹងទាសករយ៉ាងណាក៏ដោយ ។

ពលករជាច្រើន មិនបានទទួលផលប្រយោជន៍ឆ្លើយតបទៅនឹងសេចក្តីសង្ឃឹម ឬការរំពឹងទុករបស់ខ្លួន ឬក្រុមគ្រួសារឡើយ ហើយបែរជាទទួលបាននូវការឈឺចាប់ ឬខូចខាតទ្រព្យសម្បត្តិ កាយសម្បទា រហូតដល់បាត់បង់អាយុជីវិតថែមទៀត ។ ជនដែលប្រព្រឹត្តបទល្មើសមួយចំនួន មិនទាន់ត្រូវបានផ្តន្ទាទោសឲ្យសក្តិសម និងធ្វើឲ្យរាងចាលនៅឡើយ បើទោះបីជាមានការផ្តន្ទាទោសជាបន្តបន្ទាប់ តែនៅមានជនល្មើសជាច្រើនទៀត ដែលកំពុងបន្តសកម្មភាពយ៉ាងសកម្ម ដើម្បីកេងយកផលចំណេញគ្រប់ស្ថានភាព ។ ជនរងគ្រោះមួយចំនួន ទទួលបាននូវការការពារ ថែទាំ និងឧបត្ថម្ភគាំទ្រយ៉ាងសក្តិសម តែមួយចំនួនទៀត ដែលជាកុមារ យុវវ័យ ស្ត្រី និងបុរស បាននិងកំពុងតែបន្តរងគ្រោះ មិនទាន់បានទទួលការជួយសង្គ្រោះនៅឡើយ ។

ទោះបីជាយើងបានធ្វើការផ្សព្វផ្សាយជាសាធារណៈ អប់រំទូន្មាន ដាស់តឿនក្រើនរំលឹកជាប្រចាំ និងយ៉ាងទូលំទូលាយ ហើយប្រជាពលរដ្ឋស្ទើរតែគ្រប់ទីកន្លែងបានដឹង បានលឺ ឬធ្លាប់បានទទួលភាពរងគ្រោះរួចហើយ តែហាក់ដូចជានៅមិនទាន់យកចិត្តទុកដាក់ ហើយនៅតែមានអ្នកដែលបន្តផ្សងព្រេង និងជឿលើការអូសទាញពីជនខិលខូចជាជាងការដាស់តឿនឲ្យប្រុងប្រយ័ត្ន ។

មើលឃើញសភាពការណ៍បែបនេះ ទើបរាជរដ្ឋាភិបាល បានបង្កើនការយកចិត្តទុកដាក់ និងបង្កើតឲ្យមានជាយន្តការជាតិដ៏រឹងមាំមួយ ដើម្បីសម្របសម្រួល ប្រមូលផ្តុំគ្រប់កិច្ចខិតខំប្រឹងប្រែងទាំងអស់ ឲ្យមានកិច្ចសហការជាមួយគ្នាកាន់តែជិតស្និទ្ធ ចែករំលែកព័ត៌មាន និងបទពិសោធន៍ជាក់ស្តែង ដើម្បីរួមគ្នារិះរកមធ្យោបាយបំពេញចន្លោះខ្វះខាត និងបង្កើនប្រសិទ្ធភាពនៃការឆ្លើយតបឲ្យកាន់តែល្អប្រសើរ ។ រាជរដ្ឋាភិបាល ឬ ក្រសួងស្ថាប័ននានា មិនអាច

អនុវត្តវិធានការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យមានប្រសិទ្ធភាពបានឡើយ បើមិនមានការរួមសហការល្អ ក្នុងការអនុវត្តព្រមៗគ្នា និងមិនមានយុទ្ធសាស្ត្រទូលំទូលាយឆ្ពោះទៅកាន់គោលដៅរួមគ្នាទេនោះ ។ ជនល្មើសមានល្បិចកល ប្រើប្រាស់ឧបករណ៍ទំនើប មានវិធីសាស្ត្រ បត់បែន សកម្ម និងមានទំនាក់ទំនងជាប្រព័ន្ធ ទាំងតាមវិធីស្របច្បាប់ ទាំងមិនស្របច្បាប់ ។ បើមិនមានការឯកភាពជាគ្នា ជាធ្លុងមួយក្នុងការកំណត់ទិសដៅ និងវិធានការជាក់លាក់ទេ យើងនឹងនៅតែប្រឈមមុខនឹង ការបង្ក្រាប និងដោះស្រាយបញ្ហាជនរងគ្រោះកាន់តែច្រើនឡើង ធ្វើឲ្យមានស្ថានភាពច្របូកច្របល់ ហើយនឹងបន្តឲ្យមានការខាតបង់ដល់ប្រជាពលរដ្ឋ និងប្រទេសជាតិ តទៅទៀត ។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលទើបនឹងប្រកាសក្នុងថ្ងៃនេះ ត្រូវបានកំណត់ថាជាយន្តការជាតិតែមួយគត់ ដែលប្រមូលផ្តុំឲ្យមានការចូលរួមយ៉ាងទូលំទូលាយជាពហុ វិស័យ ដើម្បីអនុវត្តយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយក្នុងការបង្ក្រាប និងលុបបំបាត់អំពើជួញដូរមនុស្ស ។

ឥឡូវនេះ យើងមានផែនការសកម្មភាព និងយុទ្ធសាស្ត្រជាតិជំហានទី២ សម្រាប់រយៈពេល០៥ឆ្នាំ (២០១៤-២០១៨) ហើយដែលផែនការនេះត្រូវបានក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ រួមគ្នាដាក់បញ្ចូលនូវសកម្មភាពដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ដូច្នេះយើងត្រូវនាំគ្នាជម្រុញការអនុវត្តតាមមុខសញ្ញារៀងៗខ្លួន ហើយគប្បីខិតខំប្រឹងប្រែងឲ្យអស់ពីលទ្ធភាព ចូលរួមសហការប្រមូលផ្តុំកម្លាំង និងធនធានគ្រប់ផ្នែក ទាំងធនធានមនុស្ស ធនធានបច្ចេកទេស ទាំងធនធានថវិកា សម្ភារៈ មធ្យោបាយ ជាធនធានសរុប ឲ្យបានល្អប្រសើរ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បង្ក្រាបឲ្យបានរាល់បទល្មើសជួញដូរមនុស្ស និងអំពើល្មើសដែលពាក់ព័ន្ធ ជួយប្រជាពលរដ្ឋយើងឲ្យរួចផុតពីភាពរងគ្រោះឲ្យបាន ។ យើងមានយុទ្ធសាស្ត្រជាក់លាក់ និងមធ្យោបាយជាច្រើន ដែលយុទ្ធសាស្ត្រ និងមធ្យោបាយទាំងអស់នេះ អាចអនុវត្តបានជោគជ័យ លុះត្រាតែអ្នកអនុវត្ត មានការប្តេជ្ញាចិត្តខ្ពស់ ជម្នះឲ្យបានរាល់ឧបសគ្គ ហើយត្រូវគាំទ្រគ្នាទៅវិញទៅមក រួមដៃគ្នាបំពេញចន្លោះខ្វះខាត មិនមើលបំណាំគ្នា និងមិនគប្បីសំងំធ្វើមិនដឹងមិនលឺនោះឡើយ ។ ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នា រួមគ្នាធ្វើឲ្យប្រសើរឡើងនូវការលើកកម្ពស់ប្រសិទ្ធភាព កិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ ក្នុងការបង្ការ ទប់ស្កាត់ ការបង្ក្រាប ការសង្គ្រោះកិច្ចការពារជនរងគ្រោះ និងការផ្តន្ទាទោសជនល្មើស ។

សូមក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ដែលគ្រប់គ្រងផ្នែកហិរញ្ញវត្ថុ និងអង្គការទាំងឡាយដែលមានឆន្ទៈចូលរួមក្នុងសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឲ្យការអនុវត្តផែនការសកម្មភាពរបស់យើងទទួលបានលទ្ធផលតាមការរំពឹងទុក ។

ខ្ញុំសូមអំពាវនាវឲ្យអភិបាលរាជធានី ខេត្ត ដែលជាប្រធានគណៈកម្មាធិការថ្នាក់ក្រោមជាតិ និងជាប្រធានគណៈបញ្ជាការឯកភាព ខិតខំសម្របសម្រួល ជម្រុញ និងតាមដានសភាពការប្រែប្រួលនៃបទល្មើស និងជនល្មើសដែលកំពុងបម្លែងរូបភាពដើម្បីគេចវេសពីការចោទប្រកាន់ និងល្បិចកលទាំងឡាយរបស់ជនល្មើស ដើម្បីមានវិធានការទាន់ពេលវេលា ។

ជាថ្មីម្តងទៀត ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិ គ.ជ.ប.ជ ខ្ញុំសូមគោរពជូនពរ បវរមហាប្រសើរ សូម ឯកឧត្តម លោកជំទាវ សមាជិករាជរដ្ឋាភិបាល ឯកឧត្តម លោកជំទាវ តំណាងអង្គទូតប្រចាំកម្ពុជា អង្គការដៃគូជាតិ និងអន្តរជាតិ សមាជិក សមាជិកា ដែលមានវត្តមានទទួលបានដោយជោគជ័យ គ្រប់ភារកិច្ចការងារ ។

*សូមអរគុណ!*

# មតិចាប់អារម្មណ៍
## របស់ឯកឧត្តម ឧត្តមសេនីយ៍ឯក ថោង សំរាត ក្នុងឱកាសប្រកាស
## តែងតាំង មុខតំណែង អគ្គលេខាធិការ និងអគ្គលេខាធិការរង
## នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

-សូមគោរពឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាទីគោរពដ៏ខ្ពង់ខ្ពស់!

-សូមគោរពគណៈអធិបតី

-សូមគោរព ឯកឧត្តម លោកជំទាវជា ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ទាំងអស់ ជាទីគោរព !

- សូមគោរពលោក លោកស្រីទាំងអស់ជាទីគោរពរាប់អាន

ថ្ងៃនេះជាទិវាប្រកបដោយមហានក្ខត្តឫក្ស សម្រាប់ខ្លួនខ្ញុំបាទផ្ទាល់ក៏ដូចជាថ្នាក់ដឹកនាំជាន់ខ្ពស់ នៃ អគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលទទួលបាននូវកិត្តិយសដ៏ ខ្ពង់ខ្ពស់ និងការជឿទុកចិត្តពី ព្រះមហាក្សត្រ ពីប្រមុខរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ តែងតាំងមុខតំណែងទូលបង្គំយើងខ្ញុំជា អគ្គលេខា និង អគ្គលេខាធិការរង នៃអគ្គលេខា-ធិការដ្ឋានប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស នា ឱកាសនេះ ។

ទូលបង្គំយើងខ្ញុំទាំងអស់គ្នាមានបីតិសោមនស្សរីករាយយ៉ាងក្រៃលែងដោយ **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ និងរាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ ឈ្លាសវៃ របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ព្រមទាំងថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ជាអ្នកដឹកនាំយើងខ្ញុំផ្ទាល់ ដែលបានយកចិត្តទុកដាក់មិនត្រឹមតែកិច្ចការដឹកនាំ កសាងអភិវឌ្ឍន៍ប្រទេសជាតិ ដើម្បីសន្តិភាព សេចក្តីសុខក្សេមក្សាន្ត និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែនៅបានយកចិត្តទុក ដាក់ផ្តល់កិត្តិយស និងលើកទឹកចិត្តដល់មន្ត្រីរាជការស៊ីវិល កងកម្លាំងនគរបាលជាតិ សមស្របទៅនឹងសកម្មភាពសមត្ថភាពនៃការបំពេញភារកិច្ចតាមមុខនាទី រៀងៗខ្លួន។

ទូលបង្គំយើងខ្ញុំចាត់ទុកថានេះជាប្រភពលើកទឹកចិត្តនិងកិត្តិយសដ៏ខ្ពង់ខ្ពស់ ហើយក៏ជាកម្លាំងជំរុញមួយដ៏ខ្លាំងក្លា ដើម្បីឲ្យទូលបង្គំយើងខ្ញុំបន្តខិតខំប្រឹងប្រែងការពារ ជាតិ សាសនា ព្រះមហាក្សត្រ និងការពារប្រទេសជាតិ បម្រើប្រជាជន ហើយប្តេជ្ញាតស៊ូធ្វើពលិកម្ម ក្នុងប្រតិបត្តិការ ថែរក្សា សន្តិសុខ-សណ្តាប់ធ្នាប់សង្គម ពិសេសការប្រយុទ្ធប្រឆាំងអំពើជួញដូរ

មនុស្ស ដែលជាអំពើរំលោភ បំពានលើសិទ្ធិមនុស្ស និងជាការប្រមាថយ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ ។

ពិតប្រាកដណាស់ថាព្រឹត្តិការណ៍ដែលកើតមានឡើងថ្ងៃនេះ គឺជាសច្ចភាពបញ្ជាក់អំពីលទ្ធផលដែលឆ្លើយតបយ៉ាងសមស្របទៅនិងស្នាដៃ ដែលទូលបង្គំយើងខ្ញុំទាំងអស់គ្នា ក្រោមការជួយឧបត្ថម្ភអប់រំ ថែបំប៉ន និងវាយតម្លៃប្រកបដោយសុភវិនិច្ឆ័យ ពីសំណាក់ថ្នាក់ដឹកនាំរបស់ រាជរដ្ឋាភិបាល និងពីថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ប៉ុន្តែអត្ថន័យធំធេងដែលកំពុងតែបង្ហាញជូន ក្នុងពិធីប្រកាសមុខតំណែងនិងបំពាក់ឋានន្តរសក្តិនាឱកាសនេះ គឺជាសក្ខីកម្មឆ្លុះបញ្ចាំងឲ្យឃើញ យ៉ាងច្បាស់អំពី ទស្សនវិស័យ វែងឆ្ងាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងមហាផ្ទៃ ក្នុងការពង្រឹងយន្តការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្របតាមបរិបទសកលភាវូបនីយ៍កម្មក្នុងយុគសម័យបច្ចេកវិទ្យាទំនើប។

ការសម្រេចបង្កើតឡើងនូវអគ្គលេខាធិការដ្ឋាន ដែលជាអង្គភាពប្រតិបត្តិផ្ទាល់ជូន គណៈ-កម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនាពេលនេះ គឺជាកំណែទម្រង់ថ្មីមួយសំដៅលើកកម្ពស់ប្រសិទ្ធភាពក្នុងការស្វែងរកដំណោះស្រាយដ៏គ្រប់ជ្រុងជ្រោយដើម្បីបង្ការ-ទប់ស្កាត់ បង្ក្រាប និង ដាក់ទោស អំពើជួញដូរមនុស្ស ពិសេសស្ត្រី កុមារ និងគ្រប់ទម្រង់នៃអំពើជួញដូរផ្លូវភេទ ពលកម្ម និងសរីរាង្គ ដែលកំពុងតែបង្កនូវភាពស្មុគស្មាញជាច្រើនក្នុងសង្គមនាពេលបច្ចុប្បន្ននេះ។

**គណៈអធិបតីជាទីគោរព !**
**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីរាប់អាន!**

ឆ្លើយតបទៅនឹងគុណូបការៈដ៏ធំធេងរបស់ព្រះមហាក្សត្រ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃ តាងនាមតំណាងឲ្យមន្ត្រីជាន់ខ្ពស់ដែលទើបនឹងទទួលបានការតែងតាំងមុខតំណែងថ្មីដ៏ឧត្តុង្គឧត្តម នៅពេលនេះ ទូលបង្គំ យើងខ្ញុំ សូមធ្វើការប្តេជ្ញាចិត្ត ចំពោះមុខ ឯកឧត្តម លោកជំនាវ អស់លោក លោកស្រី ដូចតទៅ ៖

-ស្មោះស្ម័គ្រ និងធ្វើពលីកម្មគ្រប់បែបយ៉ាងដើម្បីជាតិ សាសនា ព្រះមហាក្សត្រ គោរព រដ្ឋធម្មនុញ្ញ គោរពនិងប្រតិបត្តតាមច្បាប់ ការពារសច្ចធម៌ និងយុត្តិធម៌ក្នុងសង្គម។

-ស្មោះត្រង់ជានិច្ចក្នុងបេសកកម្មបម្រើជាតិ ថែរក្សាសេចក្តីសុខក្សេមក្សាន្ត និងផលប្រយោជន៍ជាតិរបស់ប្រជារាស្ត្រ និងមាតុភូមិកម្ពុជា។

-ខិតខំដោយការទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តកម្មវិធីនយោបាយ បទបញ្ញត្តិ គោលការណ៍ផ្សេងៗ របស់រាជរដ្ឋាភិបាល របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ គោលការណ៍របស់ក្រសួងមហាផ្ទៃ ដើម្បីរួមចំណែកក្នុងការធានា បរិយាកាស សន្តិសុខល្អប្រសើរនៅក្នុងសង្គមជាតិទាំងមូល។

-ប្តេជ្ញាលះបង់កម្លាំងកាយចិត្ត គំនិតប្រាជ្ញា និងចំណេះដឹង ដើម្បីដឹកនាំស្ថាប័នរបស់ខ្លួន ឲ្យមានការអភិវឌ្ឍ លើកតម្កើង ការពារផលប្រយោជន៍ជាតិ ព្រមទាំងកិត្តិយស និងសេចក្តីថ្លៃថ្នូរ របស់ប្រជាជាតិខ្មែរ។

-ប្តេជ្ញាពង្រឹងសមត្ថភាពមុខជំនាញដល់កងកម្លាំង និងមន្ត្រីក្រោមឱវាទឲ្យមានថាមពលការងារ មានការយល់ដឹងអំពីច្បាប់ ការងារជំនាញ និងមានវិន័យ សីលធម៌ គុណធម៌ខ្ពស់ ដើម្បី សក្តិសមជាអ្នកការពារ និងបម្រើដោយស្មោះត្រង់ចំពោះប្រទេសជាតិ និងទទួលបានការទុកចិត្ត និងគោរពស្រឡាញ់ពីប្រជាពលរដ្ឋ។

-លើកកម្ពស់ស្មារតីសាមគ្គី ឯកភាពផ្ទៃក្នុង និងចរិយាធម៌ ព្រមទាំងលើកកម្ពស់មនសិការ វិជ្ជាជីវៈ ទទួលខុសត្រូវជាអ្នកដឹកនាំ ដើម្បីឲ្យការគ្រប់គ្រងគ្រប់វិស័យក្នុងស្ថាប័នទទួល បាននូវគុណភាព និងប្រសិទ្ធភាពខ្ពស់។

-បង្កើនកិច្ចសហការជាមួយអគ្គនាយកដ្ឋានចំណុះក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ និងស្ថាប័ននានា ដើម្បីធានាឲ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈសុវត្ថិភាពសង្គម សម្រួចឆន្ទៈស្នេហាជាតិ ការពារបូរណភាព អធិបតេយ្យភាពជាតិ និងរួមចំណែកយ៉ាងសកម្មក្នុងចលនា អភិវឌ្ឍន៍ប្រទេសជាតិ ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

-បន្តពង្រឹងកិច្ចសហការឲ្យបានល្អនូវកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នពាក់ព័ន្ធជាតិ-អន្តរជាតិ ដៃគូរអភិវឌ្ឍន៍នានា ដើម្បីរួមគ្នាដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវបញ្ហាប្រឈម និងក្តីកង្វល់ ជាចម្បងដែលកំពុងកើតមាននោះគឺ (១) ការបង្ការ-ទប់ស្កាត់អំពើជួញដូរមនុស្ស (២) កិច្ចការពារជនរងគ្រោះ (៣) ការផ្តន្ទាទោស (៤) ការចាត់ទុកអំពើល្មើសច្បាប់នៃអំពើជួញដូរមនុស្ស (៥) ភាពជា ដៃគូ និងសហប្រតិបត្តិការ ។

មុខតំណែងដ៏ឧត្តុង្គឧត្តម ដែលទូលបង្គំ យើងខ្ញុំទទួលបាននាពេលនេះគឺជា មុខតំណែង ដែលប្រទេសជាតិលើកទឹកចិត្ត និងផ្តល់ជូនប្រកបទៅដោយកិត្តិយស។ យើងខ្ញុំទាំងអស់គ្នា សន្យាថា មិនយកតួនាទី នេះទៅបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ឬប្រព្រឹត្តអំពើល្មើសច្បាប់ផ្សេងៗ ដែលផ្ទុយពីបំណងប្រាថ្នារបស់ព្រះមហាក្សត្រ រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ ។

ជាទីបញ្ចប់ ទូលបង្គំយើងខ្ញុំសូមអនុញ្ញាតថ្វាយព្រះពរ និងគោរពជូនពរបវរមហាប្រសើរ ជូនចំពោះគណៈ អធិបតី ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ អស់លោក លោកស្រី សូមប្រកបតែនឹងពុទ្ធពរទាំង៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!